ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION, YOUTH AND SPORT


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រ
# បង្រៀននិងរៀនតាមបែបរិះរក IBL នៅវិទ្យាស្ថាន
# គរុកោសល្យរាជធានីភ្នំពេញ (១២+៤)


ដោយ/By

គង់ ពេញ / KONG PENH


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION, YOUTH AND SPORT

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រ បង្រៀននិងរៀនតាមបែបរិះរក IBL នៅវិទ្យាស្ថាន គរុកោសល្យរាជធានីភ្នំពេញ (១២+៤)


ដោយ/By

គង់ ពេញ / KONG PENH


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

គ្រូដឹកនាំបង្គោលៈ លោក ថៃ ហេង

គ្រូដឹកនាំរងៈ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ ៥៣០៧ អយក.ខុម**

(**ការសម្គាល់**)

## លិខិតឧទ្ទេសនាម

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ទី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា « **ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រIBL នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(១២+៤)** » សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំពិតជាស្នាដៃរបស់ ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅ វិទ្យាស្ថាននេះឬសាកលវិទ្យាល័យណាឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៨កើត ខែកត្តិក ឆ្នាំជូត ទោស័កព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០

**ហត្ថលេខា**

**គង់ ពេញ**

# លិខិតបញ្ជាក់

**លោក ថៃ ហេង** **ជាគ្រូដឹកនាំបង្គោល**

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** **ជាគ្រូដឹកនាំរង**

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **គង់ ពេញ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រ** IBL **នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**(**១២**+**៤**) » ពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៨កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០

.........................................

**លោក ថៃ ហេង**

ជានាយករងវិទ្យាស្ថានជាតិអប់រំ

.........................................

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

ជានាយកវិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងអប់រំជំនាន់ទី៧ក្នុងឆ្នាំសិក្សា២០១៨ - ២០២០នៅវិទ្យាស្ថានជាតិអប់រំ សុំអោនលំទនគោរព និងថ្លែងអំណរគុណចំពោះ៖

១. ព្រះមហាក្សត្រ និងថ្នាក់ដឹកនាំរដ្ឋាភិបាលដែលខិតខំប្រឹងប្រែងតស៊ូ ការពារប្រទេសជាតិ និងរក្សាសុខសន្តិភាពជូនមាតុភូមិ ព្រមទាំងប្រជានុរាស្ត្រ ។

២. លោកឪពុក **គង់ ម៉ៅ** អ្នកម្តាយ **នៅ ញ៉** ដែលបានចិញ្ចឹមបីបាច់ថែរក្សាផ្តល់ចំណីអាហារ សម្លៀកបំពាក់ បញ្ជូនកូនទៅសាលារៀន ទូន្មានប្រៀនប្រដៅ ដើម្បីឱ្យកូនចេះដឹង ។

៣.ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកនៃវិទ្យាស្ថានជាតិអប់រំ ជាម្លប់ដ៏កក់ក្តៅ សម្រាប់វិទ្យាស្ថាន និងជាអ្នកបង្កើតរោងចក្រ ផលិតធនធានមនុស្ស សម្រាប់ប្រទេសជាតិ។

៤.លោកបណ្ឌិត **សិត សេង** នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលអនុញ្ញាត ឱ្យខ្ញុំបាទបានចុះកម្មសិក្សាស្រាវជ្រាវ និងដកយកបទពិសោធផ្ទាល់នៅអង្គភាពផ្ទាល់សម្រាប់ចងក្រង ជារបាយការណ៍។៥.គណៈគ្រប់គ្រងគ្រូឧទ្ទេសនិងគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលបានយកចិត្តទុកដាក់ចូលរួមនិងបកស្រាយរាល់កម្រងសំណួររបស់ខ្ញុំបាទ។

៦.ជាពិសេសសូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ **ថៃ ហេង** ដែលបានជួយជ្រោមជ្រែង ដឹកនាំកែសម្រួលនិងផ្តល់យោបល់ក្នុងការធ្វើសារណាបន្ថែម ដល់ខ្ញុំបាទតាំងពីដើមរហូតដល់ចប់ ថែមទាំងទទួលបានជោគជ័យជាស្ថាពរ ។

ជាទីបញ្ចប់នេះខ្ញុំបាទសូមជូនពរដល់អ្នកមានគុណទាំងទ្វេរ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអង្គការដៃគូអភិវឌ្ឍ លោកគ្រូដឹកនាំ ឯកឧត្តមបណ្ឌិត និងលោកគ្រូ អ្នកគ្រូទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ប្រការ មានសុខភាពល្អបរិបូណ៌ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងឡាយ ៤ប្រការគឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មូលន័យសង្ខេប

ការអប់រំត្រូវបានចាត់ទុកថាជាកត្តាសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលទីផ្សារការងារយ៉ាងឆាប់រហ័សនៅក្នុងសង្គមពុទ្ធិនិងបរិបទសាកលភាវូបនីយកម្ម។ដូចនេះ រាជរដ្ឋាភិបាលកម្ពុជាបានសង្កត់ធ្ងន់លើវិស័យអប់រំដូចដែលបានបង្ហាញនៅក្នុងផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិឆ្នាំ២០១៥-២០១៩។ កម្មវិធីបណ្តុះបណ្តាលវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានគោលបំណងចម្បងមួយគឺផ្តល់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំតាមរូបមន្ត ១២+៤ ដែលអនុវត្តពីជំនាន់ទី១ទៅរហូតក្នុងឆ្នាំសិក្សា ២០១៩-២០២០។

វិទ្យាស្ថានគរុកោសល្យរៀបចំផែនទីបង្ហាញផ្លូវ សម្រាប់ផែនការយុទ្ធសាស្ត្រ ២០១៨-២០២៣ ដើម្បីសម្រេចចក្ខុវិស័យក្លាយជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូឈានមុខគេក្នុងសតវត្សរ៍ទី២១។ចក្ខុវិស័យ "ជាវិទ្យាស្ថានឈានមុខគេក្នុងសតវត្សទី២១" បេសកកម្មដើម្បីសម្រេចបាននូវចក្ខុវិស័យវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានកំណត់បេសកម្មចម្បងចំនួន៣គឺៈ អប់រំគរុនិស្សិត និងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យមានគុណសម្បទាពេញលេញលើកកម្ពស់ការស្រាវជ្រាវអប់រំ ដើម្បីបង្កើនគុណភាពការបង្រៀន និងរៀនផ្តល់សេវាសហគមន៍ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ គុណតម្លៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញអនុវត្តតួនាទីភារកិច្ចដោយឈរលើគុណតម្លៃជាគន្លឹះ ចំនួន៥គឺ ការគោរព សុចរិត នវានុវត្តន៍ ការប្តេជ្ញាចិត្ត និង ប្រសិទ្ធផល។យុទ្ធសាស្ត្រ និងសកម្មភាព អភិបាលកិច្ច ការដឹកនាំ និងការគ្រប់គ្រង មានដូចជាៈ ធនធានគ្រូឧទ្ទេស កម្មវិធីអប់រំបរិស្ថានសិក្សាការអភិវឌ្ឍ សមត្ថភាពវិជ្ជាជីវៈការធានាគុណភាពផ្ទៃក្នុងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ការស្រាវជ្រាវអប់រំ ការងារ វិក្រឹតការគ្រូបង្រៀនការផ្សព្វផ្សាយស្នាដៃអប់រំ។

ការវិភាគបែបយុទ្ធសាស្ត្រមានចំណុចខ្លាំងវិទ្យាស្ថានរាជធានីភ្នំពេញ ជាវិទ្យាស្ថានមួយត្រូវបានគេបង្កើតឡើង ពីការបញ្ចូលគ្នាពីអតីតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញដែលប្រវត្តិសាស្តយូរអង្វែងនិងបទពិសោធន៍ក្នុងការបណ្តុះបណ្តាល គ្រូបឋមសិក្សានិងអនុវិទ្យាល័យនិងវិក្រឹតការគ្រូបង្រៀនក្នុងប្រទេសកម្ពុជា។មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោ

សល្បនិងវិក្រឹតការរាជធានីភ្នំពេញ មានបុគ្គលិកអប់រំមួយចំនួនដែលមានសក្តានុពលក្នុងការកែលម្អ គុណភាព អប់រំនៅក្នុងវិទ្យាស្ថានគរុកោសល្យ។ចំណុចខ្សោយវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញជាវិទ្យាស្ថានថ្មី ហើយវិទ្យាស្ថាននេះត្រូវកសាងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀតក្នុងការបង្កើត កិច្ចប្រតិបត្តិការវិទ្យាស្ថាន ដែលផ្តល់កម្មវិធីបណ្តុះបណ្តាលរយៈពេល៤ឆ្នាំសមមូលនឹងកម្រិតបរិញ្ញាបត្រក្នុងប្រទេសកម្ពុជា ឱ្យប្រព្រឹត្តទៅបានដោយរលូន។វិទ្យាស្ថាននេះមានកង្វះខាតធនធានមនុស្សដើម្បីអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្ត។កាលានុវត្តភាពក្រសួងអប់រំយុវជននិងកីឡាបានផ្តល់អាទិភាពខ្ពស់ដល់ វិទ្យាស្ថានគរុកោសល្យក្នុងការលើកកម្ពស់គុណភាពអប់រំ ដែលមាននៅក្នុងគោលនយោបាយកំណែទម្រង់ដែលអនុម័តកម្មវិធីបណ្តុះបណ្តាលតាមរូបមន្ត១២+៤។កត្តាប្រឈមសកម្មភាពវិទ្យាស្ថាននឹងមិនអាច អនុវត្តបានទេឬមានការរអាក់រអួលករណីៈមិនមានថវិកាគ្រប់គ្រាន់និងទទួលរងនូវគ្រោះមហន្តរាយ ដូចជា គ្រោះទឹកជំនន់ និងខ្យល់ព្យុះ។

សរុបសេចក្តីមកការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី « **ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រIBLនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(១២+៤)** » ឃើញថាការប្រើប្រាស់វិធីសាស្ត្រIBL មានប្រសិទ្ធខ្ពស់សម្រាប់តម្រូវការចាំបាច់នៅក្នុងវិស័យអប់រំណាស់ សម្រាប់គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញគ្រូឧទ្ទេសនិងគរុនិស្សិត។

# Abstract

Education is considered an important factor in the development of human resources in response to the rapid changes in the labor market in the Buddhist society and the context of globalization. Therefore, the Royal Government of Cambodia has emphasized the education sector as shown in the National Strategic Development Plan 2015-2019.

The main purpose of the training program of Phnom Penh Pedagogical Institute is to provide bachelor's degree training in 12 + 4 formulas, which is implemented from the first generation until the 2019-2020 school year.

The Pedagogical Institute prepares a roadmap for the Strategic Plan 2018-2023 to achieve its vision of becoming the leading teacher training institute in the 21st century. Vision "Leading Institute in the 21st Century" Mission to Achieve the Vision the Phnom Penh Pedagogical Institute has identified three main missions: to educate pedagogical students and develop the capacity of teachers to be fully qualified, to promote educational research to improve quality. Teaching and learning to provide community services to contribute to the development of teacher capacity. Values Phnom Penh Pedagogical Institute performs its duties and responsibilities based on five key values: integrity, innovation, commitment and effectiveness.

Strategies and activities of governance, leadership and management include: resources, trainers, educational programs, learning environment, professional development, internal quality assurance, collaboration with relevant institutions, research, education, vocational training, teachers, dissemination of educational works.

Strengthening Strategic Analysis Phnom Penh Capital Institute is an institution formed from a combination of the former Regional Pedagogical Center and the Phnom Penh Pedagogical and Vocational School, which have a long history and experience in training primary and secondary

teachers and Teacher training in Cambodia. The Regional Pedagogical Center and the Phnom Penh Pedagogical and Vocational School have a number of educators who have the potential to improve the quality of education in the Pedagogical Institute. Weaknesses Phnom Penh Pedagogical Institute is a new institution and it needs to build more legal documents in order to establish a smooth operation of the institute, which provides a four-year training program equivalent to a bachelor's degree in Cambodia. The institute lacks human resources to carry out the roles and responsibilities set out in the legal documents. Opportunity The Ministry of Education, Youth and Sports has given high priority to the Institute of Pedagogy in improving the quality of education in the reform policy that adopts the training program according to the 12 + 4 formula. Risk factors Institutional activities will not be feasible or disruptive Case: Lack of funds and disasters such as floods and hurricanes

In conclusion, the research on the topic "Effectiveness of using IBL method at Phnom Penh Pedagogical Institute (12 + 4)" found that the use of IBL method is very effective for the needs in the field of education for the management of the Institute. Phnom Penh pedagogy, trainers and student teachers.

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** ........ i
**លិខិតបញ្ជាក់** ........ ii
**សេចក្តីថ្លែងអំណរគុណ** ........ iii
**មូលន័យសង្ខេប** ........ iv
Abstract ........ vi
**ជំពូកទី១** ........ 1
សេចក្តីផ្តើម ........ 1
១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1
១.២ ចំណោទបញ្ហា ........ 4
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 5
១.៤ សំណួរស្រាវជ្រាវ ........ 5
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........ 5
១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 6
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 7
**ជំពូកទី២** ........ 8
រំលឹកទ្រឹស្តីដែលទាក់ទងនឹងប្រធានបទ ........ 8
២.១ សិក្សាទស្សនៈនិងទ្រឹស្តីនៃវិធីសាស្ត្របង្រៀន ........ 8
២.២ ទ្រឹស្តីនៃការបង្រៀននិងការរៀន ........ 11
២.៣ ទ្រឹស្តីគរុកោសល្យមួយចំនួន ........ 12
២.៣.១ ការគ្រប់គ្រងថ្នាក់រៀន ........ 12
២.៣.២ ភារកិច្ចរបស់គ្រូបង្រៀន ........ 14
២.៣.៣ បរិស្ថានថ្នាក់រៀន ........ 17
២.៤.២ តើការបង្រៀន និងរៀនតាមបែបរិះរក បានផ្តល់សមត្ថភាពអ្វីខ្លះដល់សិស្ស? ........ 22
**ជំពូកទី៣** ........ 25

**វិធីសាស្ត្រស្រាវជ្រាវ** ....................................................................25
៣. គម្រោងវិភាគវិធីសាស្ត្រ នៃការស្រាវជ្រាវ ....................................................................25
៣.១ ប្រភេទនៃការវិភាគ ....................................................................25
៣.២  ប្រភេទ និងប្រភពទិន្នន័យ ....................................................................25
៣.៣  ទំហំសំណាក (Sample Size) ....................................................................26
៣.៤ ការជ្រើសរើសសំណាក (Sampling) ....................................................................27
៣.៥ នីតិវិធីនៃការប្រមូលទិន្នន័យ (Data Gathering Procedure) ....................................................................28
៣.៥.១ កម្រងសំណួរស្ទាបស្ទង់មតិ (Questionnaires) ....................................................................28
៣.៥.២ ការសម្ភាស (Structured Interview) ....................................................................29
៣.៥.៣ ការសង្កេត (Observation) ....................................................................29
៣.៦ នីតិវិធីនៃការវិភាគទិន្នន័យ (Procedure of Analyzing Data) ....................................................................30
៣.៧ ឧបករណ៍ស្ថិតិ (Statistical Tools) ....................................................................30
**ជំពូកទី៤** ....................................................................32
លទ្ធផលស្រាវជ្រាវ និងការពិភាក្សា ....................................................................32
៤.១  ស្ថានភាពទូទៅរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ....................................................................32
៤.១.១ សាវតា ....................................................................32
៤.១.២ រចនាសម្ព័ន្ធគ្រប់គ្រង ....................................................................33
៤.១.៣ កម្មវិធីបណ្តុះបណ្តាល ....................................................................35
៤.១.៤ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ....................................................................36
៤.២ ផែនទីបង្ហាញផ្លូវផែនការយុទ្ធសាស្ត្រ ....................................................................37
៤.២.១ ចក្ខុវិស័យ "ជាវិទ្យាស្ថានឈានមុខគេក្នុងសតវត្សទី២១" ....................................................................38
៤.២.២ បេសកកម្ម ....................................................................38
៤.២.៣ គុណតម្លៃ ....................................................................38
៤.៣ យុទ្ធសាស្ត្រ និងសកម្មភាព ....................................................................40
៤.៣.១ អភិបាលកិច្ច ការដឹកនាំ និងការគ្រប់គ្រង ....................................................................40

៤.៣.២ ធនធានគ្រូឧទ្ទេស ........ 41

៤.៣.៣ កម្មវិធីអប់រំ ........ 42

៤.៣.៤ បរិស្ថានសិក្សា ........ 43

៤.៣.៥ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ........ 44

៤.៣.៦ ការធានាគុណភាពផ្ទៃក្នុង ........ 44

៤.៣.៧ កិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ........ 44

៤.៣.៨ ការស្រាវជ្រាវអប់រំ ........ 45

៤.៣.៩ ការងាររិក្រឹតការគ្រូបង្រៀន ........ 45

៤.៣.១០ ការផ្សព្វផ្សាយស្នាដៃអប់រំ ........ 45

៤.៤ លទ្ធផលនៃការស្រាវជ្រាវ ........ 46

៤.៤.១:តារាងស្ដីអំពីប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀន IBL ........ 46

៤.៤.២:ក្រាបសរសេរស្ដីពីការសិក្សាស្វែងយល់ពីវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ........ 47

៤.៥.ការវិភាគបែបយុទ្ធសាស្ត្រ ........ 51

៤.៥.១ ចំណុចខ្លាំង ........ 51

៤.៥.៣ កាលានុវត្តភាព ........ 53

៤.៥.៤ កត្តាប្រឈម ........ 54

**ជំពូកទី៥** ........ 55

ការសេចក្ដីសន្និដ្ឋាន និងសំណូមពរ ........ 55

៥.១ សេចក្ដីសន្និដ្ឋាន ........ 55

៥.២ សំណូមពរ ........ 56

ឯកសារយោង ........ 58

ឧបសម្ព័ន្ធ ........ 60

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

យុគ្គសម័យបដិវត្តឧស្សាហកម្ម4.0 នៃសកលភាវូបនីយកម្ម កម្ពុជាបាននឹងកំពុងខិតខំអភិវឌ្ឍខ្លួនឆ្លើយតបនឹងការរីកចម្រើន ជាមួយប្រទេសក្នុងតំបន់និងអន្តរជាតិ។ ពីមួយថ្ងៃទៅមួយថ្ងៃការរត់ប្រណាំងប្រកួតប្រជែងរវាងប្រទេសនានាក្នុងឆាកអន្តរជាតិលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ចនយោបាយ ការទូត ការអប់រំ សុខភាពសាធារណៈ រួមជាមួយនឹងសេវាកម្មផ្សេងៗដទៃទៀតការសិក្សាអប់រំបានមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ពលរដ្ឋសកលនាសតវត្សទី២១។ គ្រប់វិស័យទាំង នោះដែលអាចទទួលបានជោគជ័យនិងរីកលូតដុះដាលរឹងមាំបានគឺមិនអាចគ្មានការចូលរួមពីវិស័យអប់រំបានឡើយមានន័យសេចក្តីថាការអប់រំ គឺជាការរួមបញ្ចូលនូវចំណេះសម្បទាបញ្ញាសម្បទានិងបំណិនសម្បទាឱ្យដើរស្របទន្ទឹមគ្នាមិនអាចខ្វះមួយណាបានឡើយ ការអបរំទាំងឡាយណាដែលខ្វះសីលធម៌ គឺជាសេចក្តីវិនាសអន្តរាយក្នុងន័យនេះដែរការអប់រំដែលអាចឆ្លើយទៅនឹងបរិបទវិទ្យាសាស្ត្រ ជាតម្រូវការចាំបាច់នៃសម័យទំនើបហើយបើមានតែវិទ្យាសាស្ត្រតែខ្វះសីលធម៌មនសិការទំនួលខុសត្រូវ និងមនុស្សនិយមការអប់រំនោះបានត្រឹមតែបម្រើមហិច្ឆតានៃវិទ្យាសាស្ត្រហើយក៏អាចជា ការបំផ្លាញមនុស្សលោកវិញដែរដើម្បីធានាបាននូវការអប់រំដែលឆ្លើយតបនឹង សេចក្តីត្រូវការរបស់មនុស្សជាតិគឺការអប់រំប្រកបដោយគុណភាពនៅទូទាំងប្រទេស ក្រសួងអប់រំយុវជននិងកីឡាបានចាត់ទុកថាការអប់រំគ្រូគឺជាកត្តាសំខាន់ដើម្បីបង្កើតនិងបង្កើនគុណភាពសិក្សានៅសតវត្សទី២១។ជាក់ស្តែងនៅក្នុងឆ្នាំ២០១៥ក្រសួងអប់រំយុវជននិងកីឡាបានធ្វើកំណែទម្រង់វិស័យអប់រំកំណែទម្រង់កម្មវិធីសិក្សាកំណែទម្រង់នៃការបណ្តុះបណ្តាលគ្រូប្រកបដោយគុណភាពនិងប្រសិទ្ធ គឺជាកំណែទម្រង់ក្នុង១៥ចំណុចនៃរបៀបវារៈ ចំពោះកំណែទម្រង់វិស័យអប់រំជាតិ គោលបំណងនៃកំណែទម្រង់ទាំងអស់នោះ គឺធ្វើឱ្យមានគុណភាពនៃការសិក្សារបស់សិស្សមានភាពប្រសើរឡើងដើម្បីបំពេញតាម តម្រូវការកម្លាំងពលកម្មប្រកបដោយគុណសម្ប

ទាពេញលេញដើម្បីប្រែក្លាយកម្ពុជា ដែលជាប្រទេសមាន ប្រាក់ចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍ត្រឹមឆ្នាំ២០៥០ស្របតាមផែនការអភិវឌ្ឍជាតិ។ កំណែទម្រង់នេះត្រូវបានឆ្លុះបញ្ចាំង យ៉ាងច្បាស់ក្នុងការបង្កើតវិទ្យាស្ថានគរុកោសល្យចំនួនពីរគឺវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(P.TEC)និង វិទ្យាស្ថានគរុកោសល្យបាត់ដំបង(B.TEC)។វិទ្យាស្ថានគរុកោសល្យទាំងពីរនេះមានគោលបំណង ផ្តល់ជូនកម្មវិធី អប់រំគ្រូបង្រៀនបឋមនិងមធ្យមសិក្សាបឋមភូមិដោយផ្អែកលើកម្មវិធីអប់រំកម្រិតបរិញ្ញាបត្រផ្នែកអប់រំ (១២+៤) រួមបញ្ចូលនូវវិធីបង្រៀនល្អៗថ្មីៗតាមបែបវិទ្យាសាស្ត្រដែលប្រទេសក្នុងតំបន់និងសកលលោកកំពុងអនុវត្ត។ ជាមួយគ្នានេះដែរវិទ្យាស្ថានក៏ធ្វើវិក្រឹតការគ្រូបង្រៀនបឋម និងមធ្យមសិក្សាបឋមភូមិនិងធ្វើការស្រាវ ជ្រាវបន្តដើម្បីលើកកម្ពស់គុណភាពអប់រំនៅក្នុងវិទ្យាស្ថាន។ ( វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, ផែនការយុទ្ធសាស្ត្រ២០១៩-២០២៣,២០១៨ )។

ចក្ខុវិស័យរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញគឺជាវិទ្យាស្ថានឈានមុខគេក្នុងសតវត្សទី២១ ក្នុងនេះវិទ្យាស្ថានបានកំណត់ទិសដៅជាក់លាក់ គឺបណ្តុះបណ្តាលធនធានមនុស្សជាអ្នកផលិត ដែលមាន សមត្ថភាពអាចបង្កើតផលិតផលសម្រេចជាមួយនឹងវត្ថុធាតុដើមក្នុងស្រុកដែលមានស្រាប់តាមរយៈការបណ្តុះ បណ្តាលគ្រូបឋមសិក្សា និងគ្រូមធ្យមសិក្សាតាមបែបវិទ្យាសាស្ត្រដោយផ្អែកលើកម្មវិធីសិក្សាបែបវិធីសាស្ត្រនិងវិធីសាស្ត្ររៀននិងបង្រៀនបែបវិទ្យាសាស្ត្រ។ ជាការពិតណាស់វិស័យអប់រំមានភារកិច្ចយ៉ាងសំខាន់ ហើយគ្រូបង្រៀនតាមភូមិសិក្សានីមួយៗក៏ត្រូវបានសង្គមជាតិមានជំនឿជាក់ និងទុកចិត្តក្នុងការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាពឆ្លើយតប នឹងការប្រាថ្នាចង់បានរបស់ជាតិដែលអាចសម្រេចតាមផែនការគោលនយោបាយជាតិទាំងបច្ចុប្បន្នភាពទៅអនាគត។

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញបានបង្កើតឡើងតាមរយៈការបញ្ចូលគ្នារវាងគ្រឹះស្ថានចំនួនពីរគឺមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញដោយអនុក្រឹតលេខ៧៣ចុះថ្ងៃទី២២ខែឧសភាឆ្នាំ២០១៧។ ការបង្កើតវិទ្យាស្ថាននេះក្រសួងអប់រំយុវជននិង កីឡាបានសហការជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) តាមរយៈគម្រោងបង្កើត

វិទ្យាស្ថានគរុកោសល្យ (E-TEC) ក្នុងការសិក្សាពីតម្រូវការនិងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុ រួមមានការសាងសង់អាគារនិងប្រតិបត្តការវិទ្យាស្ថាន ដើម្បីជានាឱ្យវិទ្យាស្ថាននេះអាចដំណើរការ បានចាប់តាំងពីឆ្នាំសិក្សា២០១៨-២០១៩តទៅ។ទាំងអស់នេះគឺជា កំណែទម្រង់នៃការបណ្តុះបណ្តាលគ្រូ បង្រៀន ដែលចាកចេញពីប្រព័ន្ធ (១២+២) ទៅជាការបណ្តុះបណ្តាលគ្រូបង្រៀនប្រព័ន្ធ(១២+៤)វិញ។ ការបណ្តុះ បណ្តាលគ្រូនៅប្រទេសកម្ពុជាមានការផ្លាស់ប្តូរ និងកែលម្អជាបន្តបន្ទាប់ដូចជា គ្រូបង្រៀនរូប មន្ត ៧+១ (ឆ្នាំ១៩៨៣) , គ្រូបង្រៀនរូបមន្ត ៧+៣ , គ្រូបង្រៀន ៨+៣, គ្រូបង្រៀនរូបមន្ត១២+២ បច្ចុប្បន្នវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ( សៀវភៅណែនាំគរុកោសល្យ,២០១៩ )។ ដោយសារតែ កម្មវិធីបណ្តុះបណ្តាលនេះមិនទាន់សម្រេចបានតាមគុណវុឌ្ឍិគ្រូបង្រៀននៅថ្នាក់តំបន់រាជរដ្ឋាភិបាលបាន ដាក់ចេញអនុក្រឹតលេខ៧២និង៧៣អនក្របកចុះថ្ងៃទី២២ខែឧសភាឆ្នាំ២០១៧ស្តីពីការ ដំឡើងកម្រិតប ណ្តុះបណ្តាល និងផ្លាស់ប្តូរមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូមានស្រាប់ចំនួនបួនឲ្យទៅជាវិទ្យាស្ថាន គរុកោសល្យពីរ គឺវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងវិទ្យាស្ថានគរុកោសល្យបាត់ដំបង។ការកែ ទម្រង់បណ្តុះបណ្តាលពីរូបមន្ត១២+២ ទៅជា១២+៤(បរិញ្ញា បត្រអប់រំ)គឺដើម្បីពង្រឹងការអភិវឌ្ឍគ្រូ បង្រៀននៅកម្ពុជា ឱ្យមានគុណភាពខ្ពស់ជាគ្រូដែលទទួលបានជោគជ័យតាមស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ,ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន,២០១៦)។ នៅក្នុងប្រព័ន្ធគ្រូ បង្រៀន ១២+៤ គរុនិស្សិតបំពេញកាតព្វកិច្ចសិក្សាចំណោះទូទៅ ជាផ្លូវការរយៈពេល១២ឆ្នាំ ដោយប្រឡង ជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទើបមានសិទ្ធប្រឡងចូលរៀន។គរុនិស្សិតដែលបានប្រឡងជាប់ត្រូវ ចូលរៀនក្នុងវិទ្យាស្ថានគរុកោសល្យរយៈពេលបួនឆ្នាំ និងត្រូវបំពេញឱ្យគ្រប់ចំនួនក្រេឌីត ដែលវិទ្យាស្ថាន បានកំណត់(១២០ក្រេឌីត) តាមមុខវិជ្ជារួមនិងឯកទេសចាំបាច់របស់ខ្លួន។ គរុនិស្សិតត្រូវបានទទួលការប ណ្តុះបណ្តាលជាមួយនឹងគ្រូឧទ្ទេសដែលមានគុណវុឌ្ឍិ(ចាប់ពីកម្រិតបរិញ្ញាបត្រឯកទេសជាន់ខ្ពស់ឡើង ទៅ) រួមទាំងទ្រឹស្តីអប់រំល្អៗ និងវិធីសាស្ត្របង្រៀន បែបវិទ្យាសាស្ត្រជាពិសេស គឺការស្រាវជ្រាវគរុកោសល្យ ជាដើម។

## ១.២ ចំណោទបញ្ហា

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញគឺជាវិទ្យាស្ថានដែលថ្មីស្រឡាងដែលកើតចេញពី ការរួមបញ្ចូល រវាង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងសាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ ដែលស្ថានប័នទាំងពីរនេះមានទិសដៅការងារផ្សេងពីគ្នាគឺ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិរីឯសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញ បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមមួយ ទទួលខុសត្រូវចិត្តសាស្ត្រអប់រំជំទង់មួយទៀតទទួលខុសត្រូវចិត្តសាស្ត្រអប់រំកុមារ ជាហេតុនាំឱ្យមានភាពមិនចុះសម្រុងផ្នែកបច្ចេកទេស និងវិធីសាស្ត្របង្រៀនមួយចំនួន។ ម្យ៉ាងវិញទៀតគុណវុឌ្ឍិគ្រូឧទ្ទេសមួយចំនួន ក៏មិនទាន់បានឆ្លើយតបចំគោលដៅ ឬសេចក្តីប្រាថ្នាចង់បានវិធីសាស្ត្របង្រៀនដែលត្រូវយកមកប្រើប្រាស់នៅក្នុងការបណ្តុះបណ្តាលគរុនិស្សិតត្រូវតែសំបូរបែបទាំងទ្រឹស្តី និងបច្ចេកទេសដែលទាមទារឱ្យមានការស្រាវ ជ្រាវជាបន្ថែមនិងបន្តបន្ទាប់។ សម្រាប់វិធីសាស្ត្រទៀតសោតគឺត្រូវមានលក្ខណៈច្បាស់លាស់តាមបែបផែនវិទ្យាសាស្ត្រសក្តិសមទៅនឹងបរិបទជាតិក្នុងតំបន់និងជាសកល។

ការពិត គ្រូបង្រៀនជាស្ថាបត្យករនៃព្រលឹងវិញ្ញាណ។ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមាន ភារៈបណ្តុះបណ្តាលគ្រូកម្រិតបឋមសិក្សានិងគ្រូកម្រិតមធ្យមសិក្សាបឋមភូមិ (១២+៤) មានសក្តានុពលខ្ពស់ ដែលមានសមត្ថភាព ចំណេះដឹង និងជំនាញទេពកោសល្យឆ្លើយតបនឹងប្រទេសអ្នកផលិតនាសតវត្សទី ២១ ដូច្នេះកម្មវិធីសិក្សាសម្រាប់ឆ្នាំទី១ដល់ឆ្នាំទី៤ ត្រូវមានគ្រប់គ្រាន់ហើយត្រូវបានឆ្លើយតមទៅជីវិតរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋមិនថាបច្ចុប្បន្នភាព និងទៅអនាគតការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានគុណភាពនិងប្រសិទ្ធភាព គឺជារឿងមួយដែលមិនមានលក្ខណៈងាយស្រួលសម្រាប់វិទ្យាស្ថានគរុ កោសល្យរាជធានីភ្នំពេញដែលទាមទារឱ្យវិទ្យាស្ថានមួយនេះត្រូវះ

-មានរចនាសម្ព័ន្ធគ្រប់គ្រងអប់រំច្បាស់លាស់

-មានធនធានមនុស្ស(គ្រូឧទ្ទេស)ត្រឹមត្រូវគ្រប់គ្រាន់ច្បាស់លាស់តាមមុខវិជ្ជានីមួយៗ

- មានកម្មវិធីបណ្តុះបណ្តាលត្រឹមត្រូវច្បាស់លាស់ស្របតាមសង្គមជាក់ស្តែង និងអនាគត

-ការជ្រើសរើសគរុនិស្សិតមានសមត្ថភាព ស្នាដៃ និងការប្រកួតប្រជែង ស្រាវជ្រាវច្បាស់លាស់

-មានធនធានរូបវន្តគ្រប់គ្រាន់ បរិស្ថានសិក្សាល្អ ឯកសារសំបូរបែប(ខ្មែរ+បរទេស)

-មានភាគភាពការងារប្រើប្រាស់ធនធានមនុស្សចំគោលដៅ(ចំណេះនិងជំនាញច្បាស់លាស់)

-មានការត្រួតពិនិត្យ វាយតម្លៃ កែលម្អ រវាងបុគ្គលិកនិងបុគ្គលិក គរុនិស្សិត និងគរុនិស្សិត

-មានការលើកទឹកចិត្តជាពិសេសដល់បុគ្គលមានស្នាដៃ(បុគ្គលិក+គរុនិស្សិត)

ទាំងអស់នេះសុទ្ធតែជាភារៈ ដែលវិទ្យាស្ថានគរុកោសល្យត្រូវដោះស្រាយបញ្ហាជាជំណាក់កាល តាមកម្មវិធីនិងតាមផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមានគោលបំណងសំខាន់ៗពីរ គឺ៖

ចំណុចទី១: សិក្សាពីវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ដែលវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានកំពុងប្រើប្រាស់ក្នុងការបណ្តុះបណ្តាលគរុនិស្សិត(១២+៤)កម្រិតបរិញ្ញាបត្រអប់រំ។

ចំណុចទី២: សិក្សាប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបរិះរក(IBL) និងអំពីសារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្ររៀន និងបង្រៀនតាមបែបរិះរក។

## ១.៤ សំណួរស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះ មានសំណួរមួយចំនួនដែលអាចឆ្លើយតបទៅនឹងបញ្ហាពាក់ព័ន្ធ៖

ក. តើវិធីសាស្ត្ររៀន និងបង្រៀនតាមបែបរិះរក គឺជាអ្វី?

ខ.តើវិធីសាស្ត្ររៀននិងបង្រៀនតាមបែបរិះរកមានលក្ខណៈមានសារៈសំខាន់ដូចម្តេច?

គ.តើការយល់ឃើញរបស់គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុនិស្សិត ចំពោះការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBLមានលក្ខណៈដូចម្តេច?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ដែលអាចឆ្លើយតបទៅចក្ខុវិស័យ របស់

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញដែលបានកំណត់ថា**ជាវិទ្យាស្ថានឈានមុខគេក្នុងសតវត្សទី២១** ព្រោះថាការសិក្សាស្រាវជ្រាវនេះអាចឃើញការប្រើប្រាស់វិធីសាស្ត្របង្រៀនច្រើនយ៉ាងនិងសំបូរបែបរបស់គ្រូឧទ្ទេសក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិត១២+៤ (បរិញ្ញាបត្រអប់រំ) តាំងពីឆ្នាំទី១ដល់ទី៤ហើយគរុនិស្សិត ទាំងនោះ ក៏អាចមានលទ្ធភាពសិក្សាស្វែងយល់ពីវិធីសាស្ត្របង្រៀនផ្សេងៗជាពិសេសគឺវិធីសាស្ត្ររៀន និងបង្រៀនតាម បែបរិះរក(IBL) ។ជាការពិតណាស់ខណៈដែលគរុនិស្សិតទាំងឡាយដែលយល់ជ្រួតជ្រាបច្បាស់លាស់ និងប្រាកដប្រជា ត្រឹមត្រូវពួកគេអាចប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកក្នុងលំនាំទាំងប្រាំយ៉ាង ដែលអ្នកវិទ្យាសាស្ត្រគ្រប់រូប តែងតែប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវ និងវិភាគទិន្នន័យរបស់ពួកគេ ដូចជាៈ

- ការកំណត់បញ្ហា
- ការបង្កើតសម្មតិកម្ម
- ការធ្វើតេស្តសម្មតិកម្ម
- ការសង្កេតនិងវាស់វែងលទ្ធផល
- ការវិភាគ និងទាញសេចក្តីសន្និដ្ឋាន

រាល់លំនាំតាមបែបវិទ្យាសាស្ត្រមួយនេះ ប្រសិនបើគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានប្រើប្រាស់យ៉ាងសកម្មជាមួយនឹងសិស្សានុសិស្សរបស់ពួកគេពីមួយឆ្នាំទៅមួយឆ្នាំពីមួយជំនាន់ទៅមួយជំនាន់នោះប្រទេសជាតិរបស់យើងនឹងសំបូរទៅដោយធនធានមនុស្សបែបវិទ្យាសាស្ត្រសំបូរដោយអ្នកផលិត ពោរពេញដោយសក្តានុពលដែលអាចធ្វើឱ្យសម្រេចបាននូវគោលនយោបាយជាតិស្តីពីការបង្កើនប្រាក់ចំណូលខ្ពស់តាមរយៈអ្នកផលិតក្នុងឆ្នាំ២០៣០ និងក្លាយជាប្រទេសជឿនលឿនក្នុងឆ្នាំ២០៥០ខាងមុខ។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី « ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រIBL នៅវិទ្យាស្ថានគរុកោសល្យរាជធានី ភ្នំពេញ(១២+៤) » អ្នកស្រាវជ្រាវបានកំណត់យកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ជាទីតាំងគោលដៅ នៃការសិក្សាស្រាវជ្រាវ ព្រោះថាវិទ្យាស្ថានមួយនេះកំពុងធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនបឋម

សិក្សា និងគ្រូ បង្រៀនមធ្យមសិក្សាបឋមភូមិ១២+៤ (បរិញ្ញាបត្រអបរំ) បានចំនួន១៦រាជធានីខេត្តក្នុង ចំណោម២៥រាជធានីខេត្តក្នុងព្រះរាជណាចក្រកម្ពុជា។អ្នកពាក់ព័ន្ធដែលអ្នកស្រាវជ្រាវបានកំណត់គឺគ ណៈគ្រប់គ្រងវិទ្យាស្ថានប្រធានដេប៉ាដឺម៉ង់គ្រូឧទ្ទេស គ្រូឧទ្ទេសរង និងគរុនិស្សិតគ្រូមធ្យមសិក្សាបឋមភូមិ គរុនិស្សិតកម្រិតបឋម ឆ្នាំទី១និងឆ្នាំទី២(១២+៤)។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ស្នាដៃសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជាប្រាំជំពូកធំៗគឺៈ

ជំពូកទី១ៈសេចក្តីផ្តើម

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ នឹងលើកយកលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណងសារៈសំខាន់នៃការស្រាវជ្រាវនិងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី២ៈរំលឹកទ្រឹស្តី

ក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងប្រមូលយកទ្រឹស្តីអ្នកស្រាវជ្រាវមុនៗ និងឯកសារនានាដែលពាក់ព័ន្ធនឹងប្រធានបទដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវនិងបង្កើតស្នាដៃថ្មី។

ជំពូកទី៣ៈវិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូ វិធីវិភាគទិន្នន័យ លក្ខណៈរបស់ភាគសំណាក និងក្រមសីលធម៌នៃការស្រាវជ្រាវ។

ជំពូកទី៤ៈលទ្ធផលស្រាវជ្រាវ

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយដើម្បីរកឱ្យឃើញនូវចំណុចល្អ ចំណុចដែលដែលត្រូវធ្វើការកែលម្អ នៅក្នុងស្ថានភាព ជាក់ស្តែងរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

ជំពូកទី៥ៈសេចក្តីសន្និដ្ឋាននិងសំណូមពរ

ក្នុងផ្នែកនេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើសេចក្តីសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបាន វិភាគ ព្រមទាំងលើកយកជាសណ្ដូមពរមួយចំនួនទៅកាន់អ្នកពាក់ព័ន្ធ ក្នុងគោលលបំណងរួមចំណែកធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក(IBL)ក្នុងវិទ្យាស្ថាន។

# ជំពូកទី២

# រំលឹកទ្រឹស្តីដែលទាក់ទងនឹងប្រធានបទ

## ២.១ សិក្សាទស្សនៈនិងទ្រឹស្តីនៃវិធីសាស្ត្របង្រៀន

មានបញ្ញត្តិមួយចំនួនទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនដែលរួមមានគោលវិធីបង្រៀនវិធីសាស្ត្របង្រៀនយុទ្ធវិធីបង្រៀន វិធីបង្រៀនបច្ចេកទេសបង្រៀន ល្បិច តិចនិចក្នុងការបង្រៀន និងរៀនដូចជា៖

- គោលវិធីបង្រៀន គឺជាសំណុំនៃគោលការណ៍ ជំនឿ ឬគំនិតអំពីធម្មជាតិ នៃការសិក្សាដែលត្រូវបានបកប្រែនៅក្នុងថ្នាក់( Justin.P.Doliente,2011 )។

- គោលវិធីបង្រៀន គឺផ្តោតលើទស្សនៈ របស់មនុស្សម្នាក់ ចំពោះការបង្រៀន ឬសំដៅលើអ្វីដែលមនុស្សម្នាក់ ជឿលើការបង្រៀន ដែលមានឥរិយាបថនៃការបង្រៀន (Marilou Florentino, 2001)។

- គោលវិធីបង្រៀនគឺជាការពិពណ៌នាអំពីវិធីដែលមនុស្សទទួលបានចំណេះដឹងអំពីអ្វីមួយនិងធ្វើសេច ក្តីថ្លែងការអំពីលក្ខខណ្ឌ ដែលជួយលើកកម្ពស់ការទទួលជោគជ័យ លើការសិក្សា (Harmer, 2001)
។

- វិធីសាស្ត្របង្រៀន គឺជាសេរីនៃសកម្ម ដែលទាក់ទងនឹងការរីកចម្រើនដែលអនុវត្តដោយគ្រូ និងសិស្សដើម្បីសម្រេចគោលបំណងមេរៀន( Marilou.Florentino,2001 )។

- វិធីបង្រៀនគឺជាផែនការនៃការបង្រៀនភាសា ដែលត្រូវនឹងទ្រឹស្តី (EdwardAnthony, 1968)។

- វិធីសាស្ត្របង្រៀនអាចមានន័យថារឿងខុសគ្នាចំពោះមនុស្សផ្សេងគ្នាវាមានន័យថាជាសំណុំបែបបទនៃនីតិវិធីបង្រៀន( Mackey,1975,155 )។

- វិធីសាស្ត្របង្រៀន គឺជាទ្រឹស្តីមួយទាក់ទងនឹងគោលវិធីបង្រៀនមួយដែលត្រូវបានរៀបចំឡើងដោយការធ្វើរចនានិងការអនុវត្តតាមនីតិវិធី( Richards,andRodgers,2001 )។

-វិធីបង្រៀនគឺជាល្បិចមួយ ជាមធ្យោបាយធ្វើឱ្យការងាររបស់គ្រូ និងសិស្សក្រោមការដឹកនាំរបស់គ្រូហើយសិស្សទទួលបានចំណេះដឹងចំណេះធ្វើបំណិនប្រសប់ចេះរស់នៅជាមួយគ្នាព្រមទាំងពង្រីកសតិបញ្ញាសិស្សសំដៅប្រតិបត្តិលើគ្រប់ភារកិច្ចនៃការបង្រៀន

(ប្រាក់ពៅ,ឃិនវណ្ណី,បានកក្កដា,២០១៩)។

- វិធីសាស្រ្តបង្រៀន គឺជាដំណើរការជាជំហានៗ ឆ្ពោះទៅរកលទ្ធផលនៃការសិក្សារបស់សិស្ស។នេះគឺជាគ្រោងការឬក្បួនដែលគ្រូប្រើប្រាស់នៃការណែនាំសិស្សឱ្យទទួលបានលទ្ធផលសម្រេចនៃ ការសិក្សា។ការជ្រើសរើសវិធីសាស្រ្តបង្រៀនណាមួយមកប្រើ គឺអាស្រ័យទៅលើលទ្ធផល ឬគោលបំណង(វត្ថុបំណង)។

- វិធីសាស្រ្តបង្រៀន គឺជាការអនុវត្តជាក់ស្តែងនៅក្នុងគោលវិធីបង្រៀនមួយ (Harmer, 2001)

- យុទ្ធវិធីបង្រៀន គឺជាផែនការសកម្មភាពរយៈពេលវែង ដែលត្រូវបានរចនាឡើងដើម្បីសម្រេចគោលដៅជាក់លាក់(JastinP.Doliente,2011)។

- យុទ្ធវិធីបង្រៀនគឺជាវិធីទាំងឡាយណាដែលគ្រូប្រើដើម្បីឱ្យសម្រេចគោលបំណង ឬវត្ថុបំណងនៃការបង្រៀន។ យុទ្ធវិធីនីមួយៗគឺជាដំណើកនាំមេរៀនអំពីរបៀបដែលគ្រូនឹងត្រូវបង្រៀននិងរបៀបដែលសិស្សរៀនយុទ្ធវិធីទាំងអស់មិនដូចគ្នាយោងទៅតាមតួនាទីរបស់គ្រូ និងសិស្សធ្វើក្នុងដំណើរការនៃមេរៀនប្រភេទសកម្មភាពដែលសិស្សត្រូវប្រើ និងជំនាញដែលគ្រូចាំបាច់ប្រើនិងប្រភេទសម្ភារៈដែលតម្រូវឱ្យប្រើដើម្បីឱ្យយុទ្ធវិធី បង្រៀនបាន សម្រេចដោយជោគជ័យ (Haward Thomash,1995)។

-វិធីបង្រៀនសំដៅលើទិដ្ឋភាពតែមួយនៃការបង្រៀនដោយប្រើសម្ភារៈបង្ហាញ

- វិធីបង្រៀនសុទ្ធតែអាចប្រើបានគ្រប់វគ្គនៃការសិក្សា និងគ្រប់កម្រិតសិក្សា ដែលផ្តល់ចំណេះ និងបទពិសោធក្នុងថ្នាក់រៀនជាវិជ្ជមានសម្រាប់សិស្សគ្រប់រូប(Davis,1997)។

-វិធីបង្រៀនមានលក្ខណៈសកម្មបំផុតទាល់តែវិធីនោះមានលក្ខណៈពិសេសពីរយ៉ាង៖

-ការសិក្សាតាមវិធីបង្រៀនវិជ្ជមានដល់ក្មេងនិងទាក់ទងនឹងជីវភាពរបស់ក្មេង

- ការសិក្សាតាមវិធីដែលនាំឱ្យក្មេងចូលចិត្តរៀនដោយខ្លួនឯងទៅអនាគត ( ពៅ សាគួង , ២០០៨)។

- វិធីបង្រៀន គឺជាប្រព័ន្ធវិធីក្នុងការធ្វើការមួយ។ វាបង្កប់នូវការរៀបចំជំហានជាឡជីខល។ វាជានីតិវិធីច្រើនជាង(JustinP.Doliente,2011)។

-វិធីបង្រៀន ជារបៀបជាមធ្យោបាយជាមាគ៌ាជាយុទ្ធសាស្ត្រជាល្បិចសម្រាប់យកមកប្រើក្នុងការងារអ្វីមួយនិង ដើម្បីធ្វើឱ្យសម្រេចគោលដៅសកម្មភាព ដែលបានគ្រោងទុក (វិធីសាស្ត្របង្រៀន, ២០១៩)។

- ល្បិចនៃការបង្រៀន គឺជាការអនុវត្តវិធីសាស្ត្រមួយវាជាការអនុវត្តបច្ចេកទេសដែលកើតឡើងពិតប្រាកដក្នុងការបង្រៀននិងរៀននៅក្នុងថ្នាក់រៀន( Mackey.1975 )។

- ល្បិចបង្រៀន គឺជាការបង្រៀន ដែលគ្រូជាអ្នកតម្រង់ទិសឱ្យសិស្សធ្វើការបង្ហាញ បកស្រាយ ធ្វើគ្រាប់តាមការពិភាក្សាដោយយកសិស្សជាមូលដ្ឋាន( ក្រសួងអប់រំ,១៩៩៥ )។

- បច្ចេកទេសនៃការបង្រៀន វាជានីតិវិធី ដែលបានកំណត់យ៉ាងត្រឹមត្រូវ ដែលត្រូវបានប្រើប្រាស់ដើម្បីសម្រេចសកម្មភាពឬភារកិច្ចជាក់លាក់( JustinP.Doliente,2011 )។

- បច្ចេកទេសនៃការបង្រៀន ជាភារកិច្ចទូទៅសំដៅលើទម្រង់ឯកទេសបច្ចេកទេស ឬសេរី នៃបច្ចេកទេសដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកម្មវិធីសិក្សា។ វាផ្ដោតសំខាន់លើការប្រើប្រាស់ភាសាពិតប្រាកដ ដែលសម្រាប់សម្រេចគោលបំណងប្រាស្រ័យទាក់ទងប្រកបដោយអត្ថន័យ លើសពីថ្នាក់ភាសា ( H.DBrown,2007,180 )។

- បច្ចេកទេសនៃការបង្រៀន គឺជាការអនុវត្តវិធីបង្រៀនដែលកើតឡើងភ្លាមៗដោយរួមបញ្ចូលរវាងការអនុវត្តនិងឥរិយាបថនៃដំណើរការអនុវត្តការបង្រៀនតាមវិធីសាស្ត្រជាក់លាក់មួយ

( Richards,Rodger.2001 )

-បច្ចេកទេសនៃការបង្រៀនសំដៅលើសកម្មភាពនានាដែលគ្រូនិងសិស្សអនុវត្តក្នុងថ្នាក់រៀន

( Anthony )

- បច្ចេកទេសនៃការបង្រៀន គឺជារចនាសម្ព័ន្ធនៃមេរៀន ឬជាសកម្មភាពនៅក្នុងថ្នាក់រៀនដែលរួមមាន សកម្មភាពផ្នែកវិន័យថ្នាក់ ការរៀបចំបរិក្ខារ និងកន្លែងអង្គុយ ឬជាវិធីសាស្ត្រទូទៅនៃអន្តរទំនាក់ទំនងក្នុងថ្នាក់ដោយមានការប្រតិបត្តិរចនាសម្ព័ន្ធនិងការសម្រេច បានគោលបំណងនៃមេរៀន

( Crookes and Chaudron, 1991, 52-54)។

## ២.២ ទ្រឹស្តីនៃការបង្រៀននិងការរៀន

- ការបង្រៀន គឺជាសកម្មភាពពីរកើតឡើងព្រមគ្នាស្តីពីសកម្មភាពគ្រូនិងសកម្មភាពរបស់សិស្ស។ គ្រូបង្រៀន បំផុសគំនិតឱ្យស្គាល់តម្លៃនៃចំណេះដឹងតាមរយៈវិធីសិល្បៈ ដើម្បីឱ្យសិស្សដក់ជាប់នៅក្នុងចិត្តស្មារតី ( John Steinbeck, 2011 )។

- ការបង្រៀន គឺជាសិល្បៈដ៏អស្ចារ្យបំផុតមួយ ព្រោះវាជាបណ្តាផ្សព្វផ្សាយ ដែលអាចផ្លាស់ប្តូរផ្នត់គំនិតនិងស្មារតីរបស់មនុស្ស( RobertSmitt,Ph.D&ScottImag,Ph.D,2014 )។

- ការបង្រៀន គឺជាលំនាំសកម្មភាព ដែលផ្តោតលើប្រសិទ្ធភាព គ្រូត្រូវមានវិធីប្រាំយ៉ាង៖

-ភាពច្បាស់

-ការពិភាក្សាក្នុងថ្នាក់

-ការផ្តល់ព័ត៌មានត្រឡប់វិញ

-ទម្រង់វាយតម្លៃ

-វិធីស្វែងយល់ដឹងរបស់សិស្ស( Hattie,2017 )

- ការបង្រៀន គឺគរុសិស្សឬគ្រូបង្រៀនថ្មីត្រូវមានទំនោរជឿទៅលើ«សំណុំមេរៀនខ្លះៗដែលត្រឹមត្រូវ( Stremmel,2012 )។

- ការបង្រៀន គឺជាឆាកដ៏សំខាន់មួយសម្រាប់អភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងការផ្លាស់ប្តូរ( UNESCO,2005 )។

- ការបង្រៀន គឺជាការប៉ុនប៉ងដែលបានត្រៀមទុកក្នុងរចនាសម្ព័ន្ធមួយរបស់មនុស្ស ដើម្បីជំរុញឱ្យមានការសិក្សាដល់អ្នកដ៏ទៃ( Wittrock,2013 )។

- ការបង្រៀនអាចជាមនុស្សម្នាក់ (គ្រូបង្រៀនគ្រូឧទ្ទេសគ្រូបង្រៀនសិស្សទោល)អាចជាវត្ថុ (សៀវភៅភាពយន្ត)ឬអាចជាកម្មវិធីមួយ (កម្មវិធីសិក្សា ឬកម្មវិធីសិក្សាតាមកុំព្យូទ័រ) ( Print,1995 )។

- ការបង្រៀន គឺជាសកម្មភាពមួយក្នុងការជួយបណ្តុះបណ្តាលគំនិត អភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សឱ្យមានចរិតសកម្មនិងមានចរិតម្ចាស់ការទទួលខុសត្រូវប្រកប ដោយការ ច្នៃប្រឌិតកម្រិតខ្ពស់

ក្នុងការកំណត់ វាសនានៃការសិក្សារៀនសូត្ររបស់ពួកគេ(ចាន់ រដ្ឋសុផា, គរុកោសល្យ ,១៩៩៧)

- ការបង្រៀន គឺជាវិទ្យាសាស្ត្រផង និងជាវិធីសាស្ត្រផង (វិធីសាស្ត្របង្រៀន, ២០១៩)។

- ការបង្រៀន គឺជាមាគ៌ាក្នុងការផ្តល់ចំណេះដឹងដល់សិស្សតាមរយៈការប្រើវិធីសាស្ត្រ ល្បិច ដើម្បីឱ្យសិស្សមានការអភិវឌ្ឍបញ្ញាស្មារតីនិងរាងកាយ(វិធីសាស្ត្របង្រៀន,២០១៩)។

- ការរៀន គឺជាលំនាំមួយ ដែលនាំឱ្យមានការផ្លាស់ប្តូរ ហើយការផ្លាស់ប្តូរនោះ វាទាក់ទងទៅនឹងទេព្យកោសល្យបញ្ញា ចិត្តចលករ ឬភាពឧស្សាហ៍ព្យាយាមរបស់បុគ្គលម្នាក់ៗ (បណ្ឌិត សៀង សុវណ្ណា)។

- ការរៀន គឺជាការផ្លាស់ប្តូរយ៉ាងសមស្រប និងខ្ជាប់ខ្ជួននៃសកម្មភាពខាងក្នុង ឬខាងក្រៅនៃការផ្លាស់ប្តូរនោះដែលស្តែងចេញ អាស្រ័យដោយសកម្មភាពដំណើរការទៅមុខនិងដើម្បីទទួលបាននូវគោលបំណងមួយជាក់លាក់។ ចាប់តាំងពីមនុស្សកើតមក ពេញវ័យរហូតដល់ស្លាប់ គឺមនុស្សតែងតែមានការផ្លាស់ប្តូរ នៃអំពើប្រព្រឹត្តរបស់ពួកគេដោយសកម្មភាពផ្ទាល់ខ្លួនទៅតាមវ័យការផ្លាស់ប្តូរនៃអំពើនៃសកម្មភាពនោះ(ចិត្តវិទ្យាអប់រំ ឈួន គ្រាយ, ផាន់ ចាន់ពៅ, ២០០៨)។

## ២.៣ ទ្រឹស្តីគរុកោសល្យមួយចំនួន

គរុកោសល្យជាទូទៅជាវិទ្យាសាស្ត្រមួយដែលសិក្សាអំពីការអប់រំនិងច្បាប់អប់រំ(មានកម្មវត្ថុសិក្សាកម្ម វិធីសិក្សា ច្បាប់ជាសត្យានុម័ត) (គរុកោសល្យ, ចាន់ រដ្ឋសុផា,២០០៨)។

### ២.៣.១ ការគ្រប់គ្រងថ្នាក់រៀន

ការគ្រប់គ្រងថ្នាក់រៀនគឺជាផ្នែកមួយដ៏សំខាន់នៃការបង្រៀន និងបច្ចេកទេសគ្រប់គ្រងសិស្សដែលគ្រូបង្រៀនត្រូវតែទទួលបានការហ្វឹកហាត់នូវពុទ្ធិ(Ornstein,1990)។

តាមវចនានុក្រមអប់រំរបស់Carter V បានកំណត់និយមន័យនៃការគ្រប់គ្រងថ្នាក់រៀនថាជា «កិច្ចការរដ្ឋបាល» ឬជាទិសដៅនៃសកម្មភាពដោយភ្ជាប់ជាមួយនឹងខ្លឹមសារយោងពិសេសៗ ទៅនឹងបញ្ហាមួយចំនួនដែល រួមមានដូចជាវិន័យបច្ចេកទេសសេរីការប្រើប្រាស់ការថែទាំសម្ភារៈ និងសម្ភារៈឯកសារយោងលក្ខណៈពិសេស ផ្នែករូបវន្ត នៃថ្នាក់ រៀន គេហកិច្ច និងទំនាក់ទំនងសង្គមរបស់សិស្ស (វិធីសាស្ត្របង្រៀន,

ប្រាក់ពៅ,ឃិនវណ្ណី,បានកក្កដា,២០១៩)។

មុនពេលដំណើរការបង្រៀនគ្រូបង្រៀន ត្រូវជឿជាក់ថាថ្នាក់រៀនមានបរិយាកាសនិងសុវត្ថិភាព ដូចជាគ្មានគ្រោះថ្នាក់គ្មានអំពើហិង្សាគ្មានការគំរាមមានការតុបតែងនិងមានការថែទាំយ៉ាងល្អ ( បញ្ញត្តិជានាគុណ ភាព អប់រំ, ២០១៨)។

ការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀនដែលល្អគឺត្រូវប្រាកដថាថ្នាក់រៀនមានការតុបតែង និងមានការដាក់តាំង សម្ភារៈសិក្សាបានល្អដូចជា៖ តុបតែងបាវចនាជាតិ និងព្រះឆាយាលក្ខណ៍ នៅទីតាំងដែលសក្តិសមបំផុតនិងគួរជាទីចាប់អារម្មណ៍។ថ្នាក់រៀនត្រូវមានពាក្យស្លោក និងរូបភាពតាមមុខវិជ្ជានីមួយៗដាក់តាំងស្របកម្ពស់ របស់សិស្សងាយស្រួលក្នុងការសម្អាតនិងផ្លាស់ប្តូរបានងាយស្រួលបំផុត។ ជាងនេះទៅទៀត ថ្នាក់រៀនត្រូវមាន ការដាក់តាំងនូវកម្រងស្នាដៃសិស្សដើម្បីឱ្យសិស្សខិតខំប្រកួតប្រជែងការរៀនសូត្របានលទ្ធផលល្អ និងរៀបចំ ទុកដាក់ថែទាំសម្ភារឧបទេស និងគ្រឿងសង្ហារឹមព្រមទាំងមានអនាម័យទាំងក្នុងនិងក្រៅថ្នាក់ថែមទៀត។ គ្រូបង្រៀនត្រូវចេះរៀបចំក្តារខៀនទីកន្លែងសម្រាប់អង្គុយតុកៅអីសមស្របតាមកម្ពស់និងចំនួនសិស្ស។ ចំណែកក្តារខៀនត្រូវមានពណ៌ច្បាស់តម្រូវតាមសកម្មភាពបង្រៀន និងរៀនដើម្បីឱ្យសិស្សងាយស្រួលមើល និងហាត់ សរសេរបាន(ក្រសួងអប់រំ,ស្វ័យវាយតម្លៃសាលារៀន២០១៤)។

ការគ្រប់គ្រងរដ្ឋបាលថ្នាក់ដែលមានប្រសិទ្ធភាព គឺអាស្រ័យលើគ្រូចេះរៀបចំតារាងទាំងប្រាំបួនបញ្ជី សៀវភៅរដ្ឋបាល សៀវភៅអត្ថបទ សៀវភៅវត្តមាននិងបានកត់ត្រាជាប្រចាំ។លើសពីនេះត្រូវកត់ត្រាលទ្ធផលសិក្សារបស់សិស្សជាប្រចាំបញ្ជូនសៀវភៅតាមដានការសិក្សាសៀវភៅសិក្ខាគារិកដល់មាតាបិតាសិស្សដើម្បីឱ្យ ពួកគេជួយសហការជាមួយគ្រូបង្រៀន ក្នុងការតាមដានការសិក្សារបស់សិស្ស។គ្រូបង្រៀនត្រូវចេះប្រើប្រាស់ និងរក្សាទុកសំណុំឯកសា លិខិតផ្សេងៗរបស់សិស្សដើម្បីតាមដាននិងលើកកម្ពស់ការសិក្សាបន្តរបស់សិស្ស (ក្រសួងអប់រំ,ស្វ័យវាយតម្លៃ សាលារៀន, ២០១៤)។

នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនត្រូវមានបន្ទប់មុខវិជ្ជា ដើម្បីងាយស្រួលក្នុងការបង្រៀននិងរៀន។ជាពិសេសការងារប្រតិបត្តិតាមមុខវិជ្ជាជាក់ស្តែងដើម្បីឱ្យគរុសិស្សយល់កាន់តែច្បាស់លាស់នូវខ្លឹមសារដែលនឹងសម្រេចតាមវត្ថុបំណងមេរៀនយ៉ាងមានប្រសិទ្ធភាព។បន្ទប់មុខវិជ្ជាគឺជាបន្ទប់

រៀនមួយដែលរៀប ចំឡើងដើម្បីឱ្យដំណើរការបង្រៀន និងរៀនលើមុខវិជ្ជាមួយជាក់លាក់។ បន្ទប់តាមមុខវិជ្ជាត្រូវបានរៀបចំ សម្រាប់មុខវិជ្ជាឯកទេសនិមួយៗ។មុខវិជ្ជានីមួយៗចាំបាច់ត្រូវមានសម្ភារបង្រៀន និងរៀនដើម្បីឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាពបន្ទប់មុខវិជ្ជានីមួយៗ ជាទូទៅជាបន្ទប់ដែលមានសម្ភារៈជាច្រើន ដែលអាចសម្រួល ដល់ការបង្រៀននិងការងារក្រុមហើយសម្ភារៈដែលមានគឺសម្ភារៈគ្រូឧទ្ទេសនិងគរុសិស្ស។ការរៀបចំបន្ទប់តាម មុខវិជ្ជាគឺមានន័យថាការរៀបចំឱ្យគ្រូបង្រៀននៅតាមបន្ទប់មុខវិជ្ជារបស់ខ្លួន។ សិស្សជាអ្នកចល័តពីបន្ទប់មួយ ទៅបន្ទប់មួយទៀតទៅតាមមុខវិជ្ជាដែលពួកគេត្រូវរៀន។ បន្ទប់តាមមុខវិជ្ជាត្រូវរៀបចំសម្ភារក្នុងថ្នាក់ដើម្បីឱ្យ សិស្សអាចស្វ័យសិក្សាបាន។នេះគឺការរៀបចំធ្វើ ឱ្យសិស្សអាចរៀបចំសម្ភារបានងាយដូចជាវចនានុក្រមផែន ទីពិភពលោកតារាងជាតុគីមី...។ការរៀបចំតុស្វ័យសិក្សានៅផ្នែកខាងក្រោយនិងចំហៀងនៃបន្ទប់រៀនហើយ ដាក់តាំងសម្ភារៈឱ្យមានរបៀបរៀបរយ។ការធ្វើបែបនេះគឺជាវិធី មួយដែលអាចជួយសម្រួលដល់ស្វ័យសិក្សា របស់សិស្ស។ចាត់តាំងសិស្សម្នាក់ឬច្រើននាក់ឱ្យទទួលខុសត្រូវក្នុងការ ថែរក្សានិងការពារសម្ភារទាំងអស់ដែល បានដាក់តាំងសម្រាប់ប្រើប្រាស់ជាទូទៅ (ក្រសួងអប់រំ,កុមារមេត្រី,២០១២)។ ដូច្នេះការគ្រប់គ្រងថ្នាក់រៀន ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការទាក់ទាញសិស្សឱ្យមានចំណាប់អារម្មណ៍ក្នុងការរៀនសូត្របង្ក បរិយាកាសរីករាយនិងមានសុវត្ថិភាពដល់ការសិក្សារបស់សិស្ស។ ការគ្រប់គ្រងថ្នាក់រៀនបានល្អគឺមានន័យថាគ្រូបង្រៀនបានរក្សានូវលំនឹងថ្នាក់រៀន ដើម្បីចាប់ផ្តើមដំណើរការបង្រៀនរបស់ខ្លួនបានយ៉ាងរលូននិងសម្រេចជោគជ័យក្នុងការបំបែកវត្ថុបំណងមេរៀន។

## ២.៣.២ ភារកិច្ចរបស់គ្រូបង្រៀន

ដើម្បីឱ្យការអនុវត្តគោលវិធីសាស្ត្របង្រៀនទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ភារកិច្ចឬតួនាទីរបស់គ្រូបង្រៀនមានសារៈសំខាន់ណាស់ ក្នុងការជួយសម្រសម្រួលតម្រង់ទិសសិស្សរៀនសូត្របានកាន់ តែមានប្រសិទ្ធភាពខ្ពស់។ គ្រូបង្រៀនមានភារកិច្ចដូចខាងក្រោមៈ

*តាមដានការសិក្សារបស់ **លោកHarmer**, 2005បានកំណត់តួនាទីរបស់គ្រូបង្រៀនមានប្រាំបី

ចំណុចនៅ ក្នុងដំណើរការបង្រៀន និងរៀនរួមមានៈ

- ជាអ្នកត្រួតពិនិត្យតាមដាន

- ជាអ្នករៀបចំចាត់ចែង

- ជាអ្នកវាយតម្លៃ

- ជាអ្នកផ្សៀងផ្ទាត់គាំទ្រ

- ជាអ្នកចូលរួម

- ជាអ្នកមានធនធាន

- ជាអ្នកបង្ហាត់បង្រៀន និងអង្កេត

*តាមរយៈ**លោកមាយ សារី**, ២០០២ បានបញ្ជាក់ថា គ្រូបង្រៀនមានតួនាទីបួនយ៉ាង គឺៈ

- ជាអ្នកធ្វើផែនការ

- ជាអ្នកសម្របសម្រួល

- ជាអ្នកដឹកនាំ

- ជាអ្នកត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

***បណ្ឌិតចាន់រដ្ឋសុផា**,២០០៨បានរកឃើញថាភារកិច្ចគ្រូបង្រៀនក្នុងគោលវិធីសិស្សមជ្ឈមណ្ឌលមានប្រាំចំណុចសំខាន់ៗគឺៈ

- ជាអ្នកដាក់បញ្ហា

- ជាអ្នកជួយណែនាំ

-ជាអ្នកជួយបំផុសគំនិត

- ជាអ្នកសម្របសម្រួល

- ជាអ្នកបូកសរុប

*តាមរយៈឯកសាររបស់នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ,ការងារគ្រប់គ្រងរដ្ឋបាល, ២០០៣បានសរសេរចងក្រងថាគ្រូបង្រៀនមានភារកិច្ចៈជាកម្លាំងអប់រំចម្បងជាអ្នកជួយសិស្សដោយផ្ទាល់

ឱ្យសម្រេចភារកិច្ចរៀនសូត្ររបស់ខ្លួនដែលជាភារកិច្ចស្នូលរបស់សាលារៀន។

- ជាអ្នកបច្ចេកទេសត្រូវតែបង្រៀនមុខវិជ្ជានីមួយៗតាមវិធីសាស្ត្រដែលក្រសួងអប់រំយុវជន និង កីឡាបានកំណត់។ គ្រូបង្រៀនមិនអាចអភិវឌ្ឍន៍សម្បទាចិត្ត-គរុកោសល្យរបស់ខ្លួនឯងបានទេប្រសិន បើគាត់មិន បង្រៀនតាមវិធីសាស្ត្រ។ដើម្បីឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាពថែមទៀតទាមទារ ឱ្យគ្រូបង្រៀនមានការស្រាវជ្រាវឯកសារដែលទាក់ទងនឹងវិធីសាស្ត្របង្រៀនឱ្យបានច្រើន។

-ត្រូវទទួលខុសត្រូវក្នុងការបញ្ចប់កម្មវិធីសិក្សាប្រកបដោយគុណភាព បើមិនដូច្នោះទេអនាគតនៃការ សិក្សារបស់សិស្សនឹងត្រូវវង្វេង ហើយដែលជាទូទៅមិនសូវបានទទួលបានការកែលម្អផង។

*តាមឯកសារវគ្គបំប៉នសមត្ថភាពគ្រូកម្រិតមូលដ្ឋាន,២០១០របស់នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ បានសរសេរថា គ្រូបង្រៀនមានតួនាទីប្រាំយ៉ាងគឺ៖

- ជាអ្នកជំរុញ និងលើកទឹកចិត្តសិស្ស

- ជាអ្នកផ្សព្វផ្សាយ

- ជាអ្នកផ្តើមគំនិត

- ជាអ្នកវិភាគ

- និងជាអ្នកកែលម្អ

គុណសម្បត្តិរបស់គ្រូបង្រៀន ( Qualitites of the Teacher ) ដើម្បីឱ្យការបង្រៀនមានប្រសិទ្ធភាព គ្រូបង្រៀនត្រូវមានគុណសម្បត្តដូចខាងក្រោម៖

- មានចំណេះដឹងលើមុខវិជ្ជា ដែលត្រូវបង្រៀន

- មានជំនាញក្នុងការទាក់ទងរវាងសិស្សនិងគ្រូហើយមានការយល់សដឹងពីចិត្តគំនិតសិស្ស

- មានជំនាញគរុកោសល្យច្បាស់លាស់

-មានបំណិនប្រសប់ក្នុងការគ្រប់គ្រងសិស្សជាក្រុមតូចឬក្រុមធំដើម្បីសម្រេចកិច្ចការជាអតិបរមា ហើយនឹងធ្វើឱ្យមានការរំខានជាអប្បបរមា។ លើសពីនេះទៀត គ្រូត្រូវផ្តល់ភាពកក់ក្តៅដល់សិស្ស ដែលក្នុងនោះ មានការលើកទឹកចិត្តនិងការទទួលស្គាល់ពីតម្លៃសិស្សគ្រប់ប្រភេទ

(សៀវភៅពាក្យគន្លឹះក្នុងវិស័យអប់រំ, ១៩៩៤)។

ដូចនេះគ្រូបង្រៀន មានតួនាទីជាច្រើននៅក្នុងការអប់រំដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យអប់រំឱ្យ កាន់តែមានប្រសិទ្ធភាពវឌ្ឍនភាពប្រសើរកើនឡើង។ ប្រការសំខាន់គ្រូឧទ្ទេសនៃសាលាបណ្ដុះបណ្ដាលគ្រូ បង្រៀនទាំងអស់ត្រូវពន្យល់និងបង្ហាញគរុសិស្សអំពីតួនាទីរបស់គ្រូ ក្នុងការបង្រៀននិងអត្ថប្រយោជន៍របស់តួនាទីដើម្បីឱ្យពួកគេមានបំណិនប្រសប់ការទទួលខុសត្រូវខ្ពស់ និងដឹកនាំសិស្សានុ សិស្ស ឆ្ពោះទៅរកឧត្ដមភាព សិក្សាយ៉ាងពិតប្រាកដ។

## ២.៣.៣ បរិស្ថានថ្នាក់រៀន

ថ្នាក់រៀន គឺជាសង្គមតូចមួយហេតុនេះហើយសិស្សនៅក្នុងថ្នាក់ក៏អាចទាក់ទងគ្នាទៅវិញទៅមកតាមវិធីផ្សេងៗគ្នាដែរ។ ពួកគេក៏មានឥទ្ធិពលទៅលើគ្នាទៅវិញទៅមកដែរការជះឥទ្ធិពលនោះក៏កើតឡើងតាមរបៀបខុសៗគ្នាផងដែរ។បរិយាកាសសំដៅលើឥរិយាបថ ឬវេទនារម្មណ៍ទូទៅនិងបរិយាកាសខាងក្នុងថ្នាក់រៀន។ បរិយាកាសអាចមកពីអាការៈខាងក្រៅនៃរូបរាងថ្នាក់រៀន សិស្សានុសិស្សនៅពេល ដែលពួកគេកំពុងរៀន។ ពាក្យនេះអាចមកពីពាក្យវេទនារម្មណ៍របៀបនិយាយដែលបង្កើតឡើងដោយគ្រូបង្រៀននិងសិស្សដែលជាអ្នកធ្វើអន្តរកម្មជាមួយគ្នាទៅវិញទៅមកតាមវិធីផ្សេងៗ(វីធីប្រើប្រាស់ពាក្យគន្លឹះក្នុងវិស័យអប់រំ, ១៩៩៥)។

## ២.៤ វិធីសាស្ត្របង្រៀនតាមបែបរិះរក Inquiry-Based Lesson ( IBL )

### ២.៤.១ តើសកម្មភាពការបង្រៀន និងរៀនយ៉ាងដូចម្ដេច ទើបប្រសើរ?

ក. តើការបង្រៀនខាងក្រោមនេះមួយណាប្រសើរជាងគេ?




**ខ. តើការរិះរកជាអ្វី? (What is Inquiry?)**

-ការរិះរកគឺជាសិល្បៈនិងវិទ្យាសាស្ត្រក្នុងការសួរសំណួរ ស្តីពីពិភពធម្មជាតិនិងស្វែងរកចម្លើយនៃសំណួរទាំងនោះ។

- ការរិះរកត្រូវការការសង្កេត ពិចារណា វាស់វែងយ៉ាងម៉ត់ចត់ ការបង្កើតសម្មតិកម្ម ការបកស្រាយ និងការសំយោគជាទ្រឹស្តីរួម (សេចក្តីសន្និដ្ឋាន)។

- ការពិសោធ ការឆ្លុះបញ្ចាំង និងការទទួលស្គាល់ចំណុចខ្លាំង/ខ្សោយ គឺជាយុទ្ធវិធីសំខាន់នៃដំណើរការរិះរក។

## គ.ទម្រង់ការបង្រៀននិងរៀន"តាមបែបរិះរក"




### ឃ. វិធីសាស្ត្រ (៥ ជំហាន)

- កំណត់បញ្ហា
- បង្កើតសម្មតិកម្ម
- តេស្តសម្មតិកម្ម-ពិសោធ
- សង្កេត និងវាស់វែង-លទ្ធផល
- វិភាគ និងទាញសេចក្តីសន្និដ្ឋាន។

ង.តើមានអ្វីខុសគ្នា ?




ច.អន្តរកម្មរវាងគ្រូនិងសិស្ស




ឬ




ឆ.លក្ខណៈខុសគ្នារវាងការបង្រៀននិងរៀនតាមបែបវិៈរក និងការបង្រៀន និងរៀនតាមបែបគ្រូមជ្ឈមណ្ឌល

| | តាមបែបរិៈរក | តាមបែបគ្រូមជ្ឈមណ្ឌល |
|---|---|---|
| តួនាទីគ្រូ | ជាអ្នកសម្របសម្រួល | ជាអ្នកផ្ទេរ |
| តួនាទីសិស្ស | ជាអ្នកដោះស្រាយបញ្ហា | ជាអ្នកធ្វើតាម |
| ការចូលរួមរបស់សិស្ស | សកម្ម | អសកម្ម |
| ទំនួលខុសត្រូវរបស់សិស្ស | មានការទទួលខុសត្រូវខ្ពស់ | ខ្វះការទទួលខុសត្រូវ |
| គោលដៅសិក្សា | ផ្តោតទៅលើលំនាំនៃការរៀនរបស់សិស្ស | ផ្តោតទៅលើលទ្ធផលសិក្សារបស់សិស្ស |
| ទ្រឹស្តីនៃការរៀន | ពូនផ្តុំចំណេះដឹងសិស្ស | គម្ពីរនិយម (ផ្តៀលើគម្ពីរ) |

ជ. កម្រិតនៃការបង្រៀននិងរៀនតាមបែបរិៈរក

(វិទ្យាស្ថានជាតិអប់រំ, កម្មវិធីវគ្គបំប៉នស្តីពី "វិធីសាស្ត្របង្រៀន និងអនុវត្តការសិក្សាស្រាវជ្រាវមេរៀន", ២០១៨)

## ២.៤.២ តើការបង្រៀន និងរៀនតាមបែបរិះរក បានផ្តល់សមត្ថភាពអ្វីខ្លះដល់សិស្ស?

### ក.សមត្ថភាពវិទ្យាសាស្ត្រនិងបំណិនដំណើរការវិទ្យាសាស្ត្រ






## ខ. ការរំពឹងទុកនៃការបង្រៀន និងរៀន តាមបែបរិះរក




### គ. លក្ខណៈរបស់ការរិះរក

-ការរិះរកយកចេញពីការសួរសំណួរប៉ុន្តែមិនមែនគ្រប់តែសំណួរនោះទេ វាជាសំណួរដែលសិស្សអាច ល្បង ឆ្លើយ បាននិងអាចនាំទៅដល់ការធ្វើតេស្តឬបកស្រាយបញ្ជាក់ភស្តុតាងប្រកបដោយអត្ថន័យ។

-ការរិះរកជាអ្វីដែលអ្នកស្រាវជ្រាវតែងអនុវត្តដែលជាវិធីសាស្ត្រផ្លូវការនិងជាប្រព័ន្ធក្នុងការប្រមូល យក ព័ត៌មាន សំខាន់ៗ ហៅថាចំណេះដឹង។

-តាមវិធីរិះរកសិស្សអាចអនុវត្តដូចជាអ្នកស្រាវជ្រាវដែរ ដែលសិស្សមិនត្រឹមតែសិក្សាបញ្ញត្តិដែលមាន រួច ប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏អាចបង្កើតបញ្ញត្តិដោយខ្លួនឯងផងដែរ។

-វិធីរិះរកផ្តល់ឱ្យសិស្សនូវវិធីសាស្ត្រសកម្មនិងមានដំណើរការជាក់លាក់មួយ។ពួកគេអាចអភិវឌ្ឍវិធី ដោះស្រាយ បញ្ហាធ្វើការសម្រេចចិត្តនិងបង្កើនជំនាញសិក្សាស្រា វជ្រាវ ដែលធ្វើឱ្យគេអាចក្លាយជាអ្នករៀន ពេញមួយជីវិត។

-ក្នុងដំណើរការបង្រៀនតាមវិធីរិះរកគ្រូអាចដាក់សំណួរគន្លឹះឬបំផុសឱ្យសិស្សបង្កើតសំណួរ គន្លឹះ ខ្លួន ឯង។សំណួរគន្លឹះជាទូទៅ ជាសំណួរដែលនាំឱ្យសិស្សទៅដល់ការអង្កេតពិចារណារកចម្លើយខ្លួនឯង និង នាំទៅដល់ចម្លល់ ផ្សេងទៀត។

-ការរិះរកត្រូវការចំណេះដឹងនិងជំនាញពីមុខវិជ្ជាផ្សេងៗ ( Integration of curricula ) ។ នៅពេល

អនុ វត្តសិស្សត្រូវការទាំងចំណេះដឹងគណិតវិទ្យា វិទ្យាសាស្ត្រ សង្គម ភាសារ និងជំនាញបច្ចេកទេស។

-ការរិះរក ត្រូវការជំនាញទំនាក់ទំនងដែលសិស្សត្រូវប្រើប្រាស់សំណួរមានន័យនិងធ្វើការបកស្រាយដ៏សមហេតុផលដោយផ្ទាល់មាត់ដោយការសរសេរដែលសកម្មភាពទាំងនេះពួកគេអាចបង្រៀនគ្នាទៅវិញ ទៅមក។។

-ការរិះរកអាចឱ្យសិស្សអភិវឌ្ឍវិធីខុសៗគ្នាក្នុងការដោះស្រាយបញ្ហាដូចគ្នា និងរួមសហការគ្នាដោះស្រាយដែលម្នាក់ៗមានឱកាសបង្ហាញ និងប្រើប្រាស់ទេពកោសល្យរបស់ខ្លួន។

-តាមវិធីរិះរកក៏អាចឱ្យគ្រូសិក្សាអំពីការរីកចម្រើនរបស់សិស្សបានផងដែរ-ពួកគេជានរណា? ចេះអ្វីខ្លះ? គេគិតដោយរបៀបណាទាំងនេះអាចជួយឱ្យគ្រូធ្វើការសម្របសម្រួលការរៀនរបស់សិស្សកាន់តែមានប្រសិទ្ធភាព។

-វិធីរិះរកត្រូវការការចូលរួមសកម្មពីសិស្សនិងឱ្យពួកគេរៀនទទួលខុសត្រូវលើការសិក្សាដោយខ្លួនឯង

**ឃ.តើត្រូវរៀបចំមេរៀនIBLយ៉ាងដូចម្តេច?**



# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣. គម្រោងវិភាគវិធីសាស្ត្រ នៃការស្រាវជ្រាវ

### ៣.១ ប្រភេទនៃការវិភាគ

ការស្រាវជ្រាវនេះប្រើប្រាស់ការវិភាគបែបបរិមាណវិស័យនិងបែបការពិព័ណ៌នា។ការប្រើតាមបែបបរិមាណវិស័យគឺ ដើម្បីចង្អុលបង្ហាញពីចំនួនប្រេកង់និងភាគរយនៃការយល់ឃើញរបស់អ្នកចូលរួមផ្តល់ចម្លើយ ទៅលើចំណុចលម្អិតនីមួយៗមាននៅក្នុងកម្រងសំណួរស្ទាបស្ទង់មតិចំពោះគណៈគ្រប់គ្រងគ្រូឧទ្ទេសនិងគរុនិស្សិតស្តីពី « **ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកI.B.Lនៅក្នុងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ** » ចំពោះការវិភាគបែបពិព័ណ៌នាត្រូវបានប្រើដើម្បីរៀប រាប់អំពីទស្សនៈ និងការយល់ឃើញ របស់ៈគណៈគ្រប់គ្រងមាន៖ ព័ត៌មានទូទៅគុណវុឌ្ឍិ ចំណេះដឹងស្តីពីវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក IBL

(សូមមើលលម្អិតនៅក្នុងឧបសម្ព័ន្ធ.... ស្តីពីសំណួរសម្ភាសន៍)

គ្រូឧទ្ទេស មាន៖ ព័ត៌មានទូទៅ គុណវុឌ្ឍិ

(សូមមើលលម្អិតនៅក្នុងឧបសម្ព័ន្ធ.... ស្តីពីសំណួរសម្ភាសន៍)

គរុនិស្សិត មាន៖ ព័ត៌មានទូទៅ ចំណេះដឹងផ្នែកវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក។

(សូមមើលលម្អិតនៅក្នុងឧបសម្ព័ន្ធ.... ស្តីពីសំណួរសម្ភាសន៍)

### ៣.២ ប្រភេទ និងប្រភពទិន្នន័យ

ប្រភេទទិន្នន័យទាំងពីរ ដែលជាទិន្នន័យអង្កេត (Primary Data) និងទិន្នន័យដែលមានស្រាប់ (Secondary Data) បានយកមកប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវនេះ។

ទិន្នន័យអង្កេតប្រមូលបានពីអ្នកចូលរួមផ្តល់ចម្លើយ ដែលពាក់ព័ន្ធខ្លាំងទៅនឹងការងារផ្តល់ការ

សម្ភាសនិងធ្លាប់ទទួលការបង្រៀន និងរៀនដូចជាគណៈគ្រប់គ្រងគ្រូឧទ្ទេសនិងគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យរាជធានី ភ្នំពេញ។

ទិន្នន័យដែលមានស្រាប់ប្រមូលបានពី អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់ គុណភាពអប់រំនៃកម្ពុជាក្រសួងអប់រំយុវជននិងកីឡា គ្រឹះស្ថានបណ្តុះបណ្តាលគរុកោសល្យបណ្ណាល័យទីស្តីការគណៈ រដ្ឋមន្ត្រី គេហទំព័ររបស់ស្ថាប័នទទួលស្គាល់គុណភាពអប់រំនានា។

## ៣.៣ ទំហំសំណាក (Sample Size)

ដោយសារមានការពិបាកក្នុងការកំណត់ទំហំសំណាកនៃគណៈគ្រង់គ្រងគ្រូឧទ្ទេស និងគរុនិស្សិតដែលកំពុងធ្វើគ្រប់គ្រងបង្រៀននិងរៀននៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញឱ្យបានច្បាស់លាស់ការសិក្សា ស្រាវជ្រាវនេះបានកំណត់យកទំហំសំណាកតាមគោលបំណងដើម្បីធ្វើការស្ទាបស្ទង់មតិ និងប្រមូលទិន្នន័យ អង្កេត (Primary Data) សម្រាប់ការស្រាវជ្រាវ។

ទំហំសំណាកតាមគោលបំណងដែលកំណត់យកសម្រាប់ការស្រាវជ្រាវ មានចំនួនទៅតាមប្រភេទនៃអ្នក ចូលរួមផ្តល់ចម្លើយ ដូចខាងក្រោម៖

**សម្រាប់កម្រងសំណួរស្ទាប់ស្ទង់មតិ**

- ទំហំសំណាកនៃគណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញចំនួន០៣នាក់/០៥នាក់
- ទំហំសំណាកនៃគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ចំនួន ២០នាក់/១១០
- ទំហំសំណាកនៃគរុនិស្សិតដែលកំពុងសិក្សានៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ចំនួន ១០៦នាក់/៤៥០នាក់

**សម្រាប់ការសម្ភាស (ប្រើសំណួរសម្ភាស-Structured Interview)**

- ទំហំសំណាកត្រូវសម្ភាស(n) នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ចំនួន ១០០នាក់

**ទំហំសំណាកសរុប(N)** ចំនួន១២៩នាក់អ្នកចូលរួមផ្តល់ចម្លើយទាំងបីប្រភេទខាងលើ(ចំនួន១០០នាក់សម្រាប់កម្រងសំណួរស្ទាបស្ទង់មតិ)មានប្រភពមកពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលជាគោលដៅនៃការ ស្រាវជ្រាវ។

ទោះបីជាការកំណត់ទំហំសំណាក ដើម្បីរកចំនួនអ្នកដែលត្រូវចូលរួមផ្តល់ចម្លើយមិនបានប្រើប្រាស់រូបមន្តបែប វិទ្យាសាស្ត្រណាមួយក្តីប៉ុន្តែការស្រាវជ្រាវនេះបានកំណត់យកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ គោលដៅសិក្សាដោយប្រើរូបមន្តដូចខាងក្រោម (Yamane, 1967)៖នាំឱ្យ៖

n :ចំនួនសំណាកត្រូវសម្ភាស ១០០នាក់

- គណៈគ្រប់គ្រង ចំនួន ០៣នាក់
- គ្រូឧទ្ទេស ចំនួន ៤០នាក់
- គរុនិស្សិត ចំនួន ៥៧នាក់

N:ចំនួនសំណាកសរុប ៦១១នាក់

- គណៈគ្រប់គ្រង ចំនួន ០៥នាក់
- គ្រូឧទ្ទេស ចំនួន ១៥៦នាក់
- គរុនិស្សិត ចំនួន ៤៥០នាក់

e : កម្រិតលម្អៀង (Standard Error) ១០%

ដូចនេះ ចំនួនសម្រាប់ការស្រាវជ្រាវនេះ កំណត់យក n = ១០០នាក់។

## ៣.៤ ការជ្រើសរើសសំណាក (Sampling)

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីជ្រើសរើសសំណាក តាមការវិនិច្ឆ័យ ឬតាមគោលបំណង (Judgment Sampling Method) ដើម្បីជ្រើសរើស ឬកំណត់ថា តើអ្នកណាជាអ្នកចូលរួមផ្តល់ចម្លើយ (Respondent or Participant) ដោយមិនប្រើវិធីសាស្ត្រជ្រើសរើសតាមប្រូបាបប៊ីលីតេទេ។ ហេតុផលនៃការប្រើវិធីសាស្ត្រជ្រើសរើសសំណាកតាមការវិនិច្ឆ័យ ឬតាមគោលបំណង គឺ៖

- សមញ្ញ និងងាយស្រួលក្នុងការប្រមូលទិន្នន័យ
- កាត់បន្ថយចំណាយ និងចំណេញពេលវេលា
- អ្នកចូលរួមផ្តល់ចម្លើយដែលបានជ្រើសរើសតាមគោលបំណងអាចតំណាងបាននូវទំហំសកល Universe

ក្នុងកម្រិតជឿជាក់ដែលអាចទទួលយកបានសម្រាប់ការសន្និដ្ឋានជាទូទៅពីព្រោះអ្នកផ្តល់ចម្លើយដែលបានជ្រើសរើសតាមគោលបំណងទាំងនោះសុទ្ធសឹងជាអ្នកពាក់ព័ន្ធខ្លាំងទៅនឹងការងារបង្រៀន និងរៀនតាមបែបរិះរក។

## ៣.៥ នីតិវិធីនៃការប្រមូលទិន្នន័យ (Data Gathering Procedure)

ទិន្នន័យអង្កេតប្រមូលបានតាមរយៈការប្រើប្រាស់ **កម្រងសំណួរស្ទាបស្ទង់មតិ** ជាមួយមន្ត្រីគ្រប់ គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញគ្រូឧទ្ទេសនិងគរុនិស្សិតសរុបចំនួន១០០នាក់ ***ការសម្ភាស***ជាមួយគណៈដឹកនាំចំនួន០៣នាក់គ្រូឧទ្ទេស៤០នាក់គរុនិស្សិត៥៧នាក់ និង***ការសង្កេត***ក្នុងការងារអនុវត្តជាក់ស្តែងនិងបទពិសោធ។

ទិន្នន័យដែលមានស្រាប់ប្រមូលតាមយៈ***ការអាន ការវិភាគ ការស្រង់ និងការសំយោគ*** ពីលិខិតបទដ្ឋាន គតិយុត្តទាក់ទងនឹងការបង្រៀន និងរៀនបែបរិះរក (IBL)។ល។

### ៣.៥.១ កម្រងសំណួរស្ទាបស្ទង់មតិ (Questionnaires)

កម្រងសំណួរស្ទាបស្ទង់មតិបានផ្តល់ជូនអ្នកចូលរួមផ្តល់ចម្លើយចំនួន១០០នាក់ ក្នុងនោះអ្នកចូលរួមផ្តល់ចម្លើយសម្រាប់កម្រងសំណួរស្ទាបស្ទង់មតិមានបីប្រភេទគឺគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុនិស្សិត។

- កម្រងសំណួរបានផ្តល់ជូនគណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ចំនួន០៣ កម្រងសំណួរ ត្រូវស្មើនឹង ០៣% នៃកម្រងសំណួរសរុប។
- កម្រងសំណួរបានផ្តល់ជូនគ្រូឧទ្ទេសចំនួន៤០កម្រងសំណួរត្រូវស្មើនឹង ៤០% នៃកម្រងសំណួរសរុប
- កម្រងសំណួរបានផ្តល់ជូនគរុនិស្សិតចំនួន៥៧កម្រងសំណួរត្រូវស្មើនឹង៧៥% នៃកម្រងសំណួរសរុប

កម្រងសំណួរស្ទាបស្ទង់មតិសម្រាប់គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានបីផ្នែក ក្នុងនោះផ្នែកទី១ទាក់ទងព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងវិទ្យាស្ថាន(មាន០៣ចំណុចលម្អិត) ផ្នែកទី២ ទាក់ទងនឹងគុណវុឌ្ឍិ(មាន០៣ចំណុចលម្អិត)ផ្នែកទី៣ចំណេះដឹងស្តីពីវិធីសាស្ត្របង្រៀន និង

រៀនតាមបែប រិះរកIBL( មាន២ ចំណុចលម្អិត ) និងផ្នែកទី៤ទាក់ទងនឹងសំណូមពរ។

កម្រងសំណួរស្ទាបស្ទង់មតិសម្រាប់គ្រូឧទ្ទេសចែកចេញជា០៤ផ្នែកដូចគ្នា។ ផ្នែកទី១ទាក់ទងនឹងព័ត៌ មានទូទៅរបស់គ្រូឧទ្ទេស (មាន០៥ចំណុចលម្អិត) ផ្នែកទី២ទាក់ទងនឹងអំពីគុណវុឌ្ឍិ(មាន០៤ ចំណុច លម្អិត)ផ្នែកទី៣ ទាក់ទងនឹងចំណេះដឹងស្ដីពីវិធីសាស្រ្ត បង្រៀនតាមបែបរិះរកIBL (មាន០២ ចំណុចលម្អិត) ផ្នែកទី៤ទាក់ទងនឹងសំណូមពរ។នៅផ្នែកបញ្ចប់នៃកម្រងសំណួរស្ទាបស្ទង់មតិមានចំណុច ដែលសួរ អ្នកចូល រួមផ្ដល់ចម្លើយដើម្បីផ្ដល់យោបល់បន្ថែម។រៀងរាល់ចំណុចលម្អិតនីមួយៗអ្នកចូលរួម ផ្ដល់ចម្លើយអាច ដាក់ពិន្ទុ ពី១ទៅ៥ដើម្បីបញ្ជាក់ពីការយល់ឃើញរបស់ខ្លួន។ពិន្ទុ១=ពុំមានយោបល់.ពិន្ទុ ២=មិនយល់ស្របទាំងស្រុង.ពិន្ទុ៣=យល់ស្របខ្លះៗ.ពិន្ទុ៤=យល់ស្រប និងពិន្ទុ ៥=យល់ស្របទាំងស្រុង។

( សូមមើលឧបសម្ព័ន្ធ.... ស្ដីពីកម្រងសំណួរស្ទាបស្ទង់មតិ )

### ៣.៥.២ ការសម្ភាស ( Structured Interview )

ការសម្ភាសត្រូវបានធ្វើឡើងជាមួយគណៈគ្រប់វិទ្យាស្ថាន ចំនួន ០៣នាក់ ដែលទទួល មានបទ ពិសោធ បង្រៀន និងរៀន តាមបែបរិះរក។ ការសម្ភាសធ្វើឡើងតាមរយៈសំណួរសម្ភាស ដែលរៀបចំទុកជា មុន ( StructuredInterviewSurvey )និងនៅផ្នែកបញ្ចប់នៃសំណួរសម្ភាសមានចំណុចដែល ត្រូវឱ្យអ្នក ចូលរួម ផ្ដល់ចម្លើយធ្វើការផ្ដល់ យោបល់បន្ថែម ករណីពួកគាត់យល់ថាចាំបាច់។

( សូមមើលឧបសម្ព័ន្ធ.... ស្ដីពីសំណួរសម្ភាសន៍ )។

សំណួរសម្ភាស និងកម្រងសំណួរស្ទាបស្ទង់មតិបានបង្កើត និងរៀបចំឡើង ដោយផ្អែកទៅលើគោល បំណង និងសំណួរបញ្ហានៃការស្រាវជ្រាវព្រមទាំងទ្រឹស្ដីដែលបានរំលឹកក្នុងជំពូកទី២នៃការស្រាវជ្រាវនេះ។ គោលបំណងសំខាន់នៃការធ្វើសំណួរសម្ភាសគឺមិនមែនដើម្បីប្រៀបធៀបជាមួយលទ្ធផល ដែលទទួលបាន ពីកម្រងសំណួរស្ទាប ស្ទង់មតិទេ។ ប៉ុន្តែដើម្បីផ្ដល់ព័ត៌មានបន្ថែម ឬបំពេញគ្នា ទៅវិញទៅមក។

### ៣.៥.៣ ការសង្កេត ( Observation )

ការស្រាវជ្រាវនេះក៏ប្រើវិធីសាស្រ្តក្នុងការសង្កេតដើម្បីប្រមូលទិន្នន័យដែរ ដូចជាតាមរយៈបទសោធ ផ្ទាល់ខ្លួនក្នុងការងារបង្រៀន និងរៀនកន្លងមកដល់បច្ចុប្បន្ន។ល។

## ៣.៦ នីតិវិធីនៃការវិភាគទិន្នន័យ ( Procedure of Analyzing Data )

ការស្រាវជ្រាវនេះប្រើតារាង( Tabular )និងក្រាភិចដើម្បីវិភាគទិន្នន័យដែលប្រមូលបាន សម្រាប់គោល បំណង នៃការស្រាវជ្រាវ។

ការវិភាគទិន្នន័យដែលប្រមូលបានពីកម្រងសំណួរស្ទាបស្ទង់មតិគឺជាទិន្នន័យបែបគុណភាពវិស័យ ហើយត្រូវបានបំលែងជាទិន្នន័យបែបបរិមាណវិស័យវិញដែលអាចធ្វើប្រមាណវិធីពិជគណិត បានក្នុងកម្រិត ចង្អុលបង្ហាញគឺ.ពុំមានយោបល់=១ពិន្ទុ.មិនយល់ស្របទាំងស្រុង=២ពិន្ទុ.យល់ស្របខ្លះៗ=៣ពិន្ទុ យល់ស្រប =៤ពិន្ទុនិងយល់ស្របទាំងស្រុង=៥ពិន្ទុដូចនេះទិន្នន័យដែលប្រមូលពីកម្រងសំណួរស្ទាបស្ទង់មតិចាត់ទុកជា ទិន្នន័យបែបបរិមាណ ដែលត្រូវបានយកមកវិភាគក្នុងកម្មវិធីMs Excel ដើម្បីវិភាគឱ្យចេញជាកម្រិតភាគរយ នៃការយល់ឃើញរបស់អ្នកចូលរួមផ្តល់ចម្លើយនៃកម្រិតពិន្ទុខាងលើ ទៅលើចំណុចលម្អិតនៃផ្នែកនីមួយៗក្នុង កម្រងសំណួររួចបង្ហាញជាក្រាភិចរួមតែមួយដោយប្រើដ្យាក្រាមរបារ( BarChart )។សេចក្តីលម្អិត និងលទ្ធ ផលនៃការវិភាគនេះមាន រៀបរាប់ និងពិភាក្សានៅក្នុងជំពូកទី៤។

ទិន្នន័យទាំងអស់នេះត្រូវបានប្រៀបធៀបទៅនឹងការរំលឹកទ្រឹស្តី ស្តីពីប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រIBLនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ( ១២+៤ ) និងសិក្សាបញ្ហាប្រឈមនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបរិះរក( IBL )និងដំណោះស្រាយនៃការប្រើប្រាស់វិធីសាស្ត្ររៀន និងបង្រៀនតាមបែបរិះរក។

## ៣.៧ ឧបករណ៍ស្ថិតិ ( Statistical Tools )

ឧបករណ៍ស្ថិតិដែលបានយកមកប្រើសម្រាប់ការស្រាវជ្រាវនេះគឺ ភាគរយនិងមធ្យម។ ភាគរយប្រើដើម្បី ពិព័ណ៌នាអំពីអាត្រានៃការយល់ឃើញកម្រិតចង្អុលបង្ហាញគឺពុំមានយោបល់,មិនយល់ស្របទាំងស្រុង, យល់ ស្របខ្លះៗ,យល់ស្រប,និងយល់ស្របទាំងស្រុងរបស់អ្នកចូលរួមផ្តល់ចម្លើយទាំងអស់ ទៅលើចំណុចលម្អិត នីមួយៗនៃការងារបង្រៀននិងរៀនតាមបែបរិះរក គណៈគ្រប់គ្រងគ្រូឧទ្ទេស និងគរុនិស្សិត។

រូបមន្តគណនាភាគរយ៖

ដែល P ជាភាគរយ ជាប្រេកង់នៃចំណុចលម្អិតនីមួយៗ និង n ជាចំនួនអ្នកផ្ដល់ចម្លើយ

ចំណែកឯមធ្យម ប្រើដើម្បីបង្ហាញអាត្រាពិន្ទុ ជាមធ្យមនៃការយល់ឃើញរបស់អ្នកចូលរួមផ្ដល់ចម្លើយ ទៅលើផ្នែកនីមួយៗនៃកម្រងសំណួរស្ទាបស្ទង់មតិ។

រូបមន្តគណនាមធ្យម៖ ។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

## ៤.១ ស្ថានភាពទូទៅរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

### ៤.១.១ សាវតា

ការអប់រំត្រូវបានចាត់ទុកថា ជាកត្តាសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្លើយតបទៅនឹង បម្រែបម្រួលទីផ្សារការងារយ៉ាងឆាប់រហ័សនៅក្នុងសង្គមពុទ្ធិនិងបរិបទសាកលភាវូបនីយកម្ម។ដូចនេះ រាជ រដ្ឋាភិបាលកម្ពុជាបានសង្កត់ធ្ងន់លើវិស័យអប់រំដូចដែលបានបង្ហាញ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៥-២០១៩។ គោលបំណងនៃផែនការយុទ្ធសាស្ត្រនេះ គឺធានាថាកុមារកម្ពុជាគ្រប់រូបអាចទទួលបានការអប់រំមូលដ្ឋានប្រកបដោយគុណភាពសមភាព និងឥតគិតថ្លៃដូចមានចែងក្នុងច្បាប់អប់រំដែលបានអនុម័តក្នុងឆ្នាំ២០០៧ ដែលស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិក្នុងវិស័យអប់រំ (SDG4) ក្នុងគោលបំណង់ធានាឱ្យមានការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបណ្ណ និងឱកាសរៀនពេញមួយជីវិតសម្រាប់ទាំងអស់គ្នានៅត្រឹមឆ្នាំ២០៣០។ ដូច្នេះ ក្រសួងអប់រំយុវជននិងកីឡា(អ.យ.ក)បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់ គុណភាពអប់រំដូចបានបង្ហាញនៅ ក្នុងផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៥-២០១៩។ដាក់ស្តែងក្នុងឆ្នាំ២០១៥ ក្រសួងអប់រំយុវជននិងកីឡាបានធ្វើកំណែទម្រង់កម្មវិធី សិក្សាដែលជាធាតុមួយក្នុងចំណោម១៥ចំណុចនៅក្នុងរបៀបវារៈនៃកំណែទម្រង់វិស័យអប់រំ។គោលបំណង ទាំងអស់នោះគឺធ្វើឱ្យគុណភាពនៃការសិក្សារបស់សិស្សមានភាពប្រសើរ ដើម្បីបំពេញតាមតម្រូវការកម្លាំងពលកម្មប្រកបដោយគុណសម្បទាពេញលេញ ដើម្បីប្រែក្លាយប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០និងជាប្រទេសអភិវឌ្ឍន៍នៅត្រឹមឆ្នាំ២០៥០ស្របតាម ផែនការអភិវឌ្ឍជាតិ។

ដើម្បីធានាបាននូវការអប់រំប្រកបដោយគុណភាពនៅទូទាំងប្រទេសក្រសួងអប់រំយុវជន និងកីឡាបានចាត់ទុកថាការអប់រំគ្រូបង្រៀន គឺជាកត្តាសំខាន់ដើម្បីបង្កើនគុណភាពសិក្សានៅសតវត្សរ៍ទី២១។ ម្យ៉ាងវិញទៀតគុណភាពនៃការសិក្សាគឺពឹងផ្អែកទាំងស្រុងទៅលើការផ្តល់ចំណេះដឹងជំនាញ និងឥរិយា បថដែលមាននៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀនប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះការលើកកម្ពស់គុណភាពគ្រូបង្រៀនគឺជាសសរស្តម្ភមួយ ក្នុងចំណោមសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភសំខាន់ទាំង៥នៅក្នុងកំណែទម្រង់អប់រំដែលបានកំណត់ដោយអ.យ.ក។ កំណែទម្រង់នេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ក្នុងការបង្កើត វិទ្យាស្ថានគរុកោសល្យចំនួនពីរ(០២)ដែលវិទ្យាស្ថានមួយមានទីតាំង នៅរាជធានីភ្នំពេញនិងមួយទៀតនៅខេត្តបាត់ដំបង។វិទ្យាស្ថានគរុកោសល្យទាំងពីរនេះមាន បំណងផ្តល់ជូនកម្មវិធីអប់រំដល់គ្រូបង្រៀនបឋម និងមធ្យមសិក្សាបឋមភូមិដោយផ្អែកលើកម្មវិធីអប់រំកម្រិតបរិញ្ញាបត្រផ្នែកអប់រំ(១២+៤)ធ្វើវិក្រឹតការគ្រូបង្រៀនបឋម សិក្សានិងមធ្យមសិក្សាបឋមភូមិនិងធ្វើការស្រាវជ្រាវដើម្បីបន្តលើក កម្ពស់គុណភាពអប់រំនៅក្នុងវិទ្យាស្ថាន។

វិទ្យាស្ថានគរុកោលសល្យរាជធានីភ្នំពេញ(វ.គ.ភ) ត្រូវបានបង្កើតឡើងតាមរយៈការបញ្ចូលគ្នារវាងគ្រឹះស្ថានចំនួន(០២)គឺមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញនិងសាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញដោយអនុក្រឹត្យលេខ៧៣ចុះថ្ងៃទី២២ខែឧសភាឆ្នាំ២០១៧។ ក្នុងការបង្កើតវិទ្យាស្ថាននេះ ក្រសួងអប់រំយុវជននិងកីឡាបានសហការជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)តាមរយៈគម្រោងបង្កើតវិទ្យាស្ថានគរុកោសល្យ (E-TEC) ក្នុងការសិក្សាពីតម្រូវការនិងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុរួមមានការសង់អគារ និងប្រតិបត្តិការវិទ្យាស្ថានដើម្បីធានាឱ្យវិទ្យាស្ថាននេះអាចដំណើរការបានចាប់ ពីឆ្នាំសិក្សា២១៩-២០២០ តទៅ។

### ៤.១.២ រចនាសម្ព័ន្ធគ្រប់គ្រង

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ មាននាយកវិទ្យាស្ថាន ០១រូប និងនាយករង/នាយិការងចំនួន ០៤ រូបដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមប្រឹក្សាបច្ចេកទេស។ វិទ្យាស្ថានគរុកោសល្យនេះមានការិយាល័យ ចំនួន០៣ ដេប៉ាតឺម៉ង់ចំនួន ០៧ និងមានសាលាអនុវត្តន៍ចំនួន ០២ គឺសាលាបឋមសិក្សា និងអនុ

វិទ្យាល័យ។




រូបភាព ៤.១ រចនាសម្ព័ន្ធគ្រប់គ្រងរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានមន្ត្រីអប់រំសរុបចំនួន ១៣៧នាក់ នាយកវិទ្យាស្ថាន ០១រូប នាយករង/នាយិការងចំនួន០៤រូបនិងបុគ្គលិកការិយាល័យនិងគ្រូឧទ្ទេសចំនួន១៣២នាក់ ដូចមានក្នុង តារាង ខាងក្រោម៖

តារាង៤.១ចំនួននិងកម្រិតវប្បធម៌របស់គណៈគ្រប់គ្រង និងសមាសភាពបុគ្គលិកនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ៖

| ល.រ | បុគ្គលិកអប់រំ | កម្រិតវប្បធម៌ | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | មធ្យមសិក្សាទុតិយភូមិ ឬក្រោម | | បរិញ្ញាបត្រ | | បរិញ្ញាបត្រជាន់ខ្ពស់ | | បណ្ឌិត | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប |
| ១ | គណៈគ្រប់គ្រង | ០០ | ០០ | ០០ | ០០ | ០៣ | ០១ | ០២ | ០០ | ០៥ |
| ២ | បុគ្គលិកការិ. | ០៨ | ០៦ | ១៥ | ០៦ | ១៣ | ០៤ | ០០ | ០០ | ៣៦ |
| ៣ | គ្រូឧទ្ទេស | ០៩ | ០២ | ៥៨ | ៣០ | ៤៣ | ០៩ | ០០ | ០០ | ១១០ |
| **សរុបរួម** | | | | | | | | | | ១៥១ |

ក្នុងចំណោមគ្រូឧទ្ទេសបរិញ្ញាបត្រជាន់ខ្ពស់ទាំង ៤៣នាក់ មានតែ ២៤នាក់ (ស្មើនឹង ២១.៨០% នៃចំនួនគ្រូ ឧទ្ទេសសរុប) ដែលមានជំនាញត្រូវនឹងបរិញ្ញាបត្រ។

### ៤.១.៣ កម្មវិធីបណ្តុះបណ្តាល

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានគោលបំណងចម្បងមួយ គឺផ្តល់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំតាមរូបមន្ត១២+៤ដែលអនុវត្តពីជំនាន់ទី១នៅក្នុងឆ្នាំសិក្សា២០១៩-២០២០។ ទោះបីជានៅក្នុងអតីតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យ និងវិចក្រឹតការកំពុងបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិនិងគ្រូបឋមសិក្សា១២+២ក៏ដោយក៏វិទ្យាស្ថាននេះ នៅតែបន្តការអនុវត្តកម្មវិធីបណ្តាលដដែល។

វិទ្យាស្ថានគរុកោសល្យក៏បានរៀបចំវិក្រឹតការគ្រូបង្រៀនរៀងរាល់ឆ្នាំ ដើម្បីបង្កើនសមត្ថភាពគ្រូបឋមសិក្សាឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានរយៈពេល២ឆ្នាំនៅវិស្សមកាល(កញ្ញាដល់តុលា)។ ចំនួនគ្រូបង្រៀនសរុបដែល ទទួលបានការបណ្តុះបណ្តាលដោយជោគជ័យរៀងរាល់ឆ្នាំដូចមាននៅក្នុងតារាង៖

តារាង ៤.២ ចំនួនគ្រូដែលទទួលបានការបណ្តុះបណ្តាល

| ល.រ | កម្មវិធីបណ្តុះបណ្តាល | ចំនួនគ្រូបង្រៀនបានបណ្តុះបណ្តាល |
|---|---|---|
| ១. | គ្រូបង្រៀនបឋមសិក្សា | ៣៦៣២ |
| ២. | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ៦៧០៣ |
| ៣. | បង្កើនសមត្ថភាពគ្រូបឋមសិក្សាឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន | ២២០៣ |

តារាង៤.៣ក្នុងឆ្នាំសិក្សា២០១៨-២០១៩វិទ្យាស្ថានគរុកោសល្យកំពុងដំណើរការ បណ្តុះបណ្តាល៖

| ល.រ | កម្មវិធីបណ្តុះបណ្តាល | គរុសិស្សកំពុងបណ្តុះបណ្តាល |
|---|---|---|
| | | សរុប |
| ១. | គ្រូបង្រៀនបឋមសិក្សា | ១៨០ |
| ២. | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ១៩៣ |
| ៣. | បង្កើនសមត្ថភាពគ្រូបឋមសិក្សាឱ្យទៅជាគ្រូបង្រៀនកម្រិត មូលដ្ឋាន | ៥៨៦ |

## ៤.១.៤ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

តារាង ៤.៤ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានផ្ទៃដីសរុបចំនួន ៧៣.៥៤៣ម$^{២}$ ដោយមានហេដ្ឋារចនាសម្ព័ន្ធរូប វន្តដូចខាងក្រោម៖

| ល.រ | សេចក្តីពណ៌នា | ចំនួន |
|---|---|---|
| ១. | អគារសិក្សា | ១៣ |
| ២. | បន្ទប់ការិយាល័យ | ០៥ |

| | | |
|---|---|---|
| ៣. | បន្ទប់រៀន | ៤៦ |
| ៤. | បន្ទប់ប្រជុំ | ០៣ |
| ៥. | បណ្ណាល័យ | ០៣ |
| ៦. | បន្ទប់ពិសោធន៍ | ០៥ |
| ៧. | បន្ទប់រោងជាង | ០៣ |
| ៨. | បន្ទប់ព័ត៌មានវិទ្យា | ០៣ |
| ៩. | អន្តេវាសិកដ្ឋានសម្រាប់គរុសិស្ស | ០៣ |
| ១០. | អន្តេវាសិកដ្ឋានសម្រាប់គ្រូឧទ្ទេស | ០០ |
| ១១. | ឃ្លាំងឥវ៉ាន់ | ០២ |

## ៤.២ ផែនទីបង្ហាញផ្លូវផែនការយុទ្ធសាស្ត្រ

វិទ្យាស្ថានគរុកោសល្យ រៀបចំផែនទីបង្ហាញផ្លូវ សម្រាប់ផែនការយុទ្ធសាស្ត្រ២០១៨-២០២៣ ដើម្បីសម្រេច ចក្ខុវិស័យក្លាយជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូឈានមុខគេក្នុងសតវត្សរ៍ទី២១។




រូបភាព ៤.២ ផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថានគរុកោសល្យ២០១៩-២០២០

### ៤.២.១ ចក្ខុវិស័យ "ជាវិទ្យាស្ថានឈានមុខគេក្នុងសតវត្សទី២១"

### ៤.២.២ បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញបានកំណត់បេសកកម្មចម្បងចំនួន ៣គឺ៖

– អប់រំគរុនិស្សិត និងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យមានគុណសម្បទាពេញលេញ

– លើកកម្ពស់ការស្រាវជ្រាវអប់រំដើម្បីបង្កើនគុណភាពការបង្រៀន និងរៀន

– ផ្តល់សេវាសហគមន៍ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

### ៤.២.៣ គុណតម្លៃ

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញអនុវត្តតួនាទីភារកិច្ច ដោយឈរលើគុណតម្លៃជាគន្លឹះចំនួន ៥គឺ **ការគោរព សុចរិត នវានុវត្តន៍ ការប្តេជ្ញាចិត្ត** និង **ប្រសិទ្ធផល**។

រូបភាព៤.៣គុណតម្លៃ




**ការគោរព** ៖ ការបង្ហាញពីអារម្មណ៍វិជ្ជមាន និងការទទួលស្គាល់សីលតម្លៃផ្ទាល់ខ្លួននិងអ្នកដទៃតាម រយៈសកម្មភាព និងពាក្យសម្តី។

**សុចរិត** ៖ សេចក្តីស្មោះត្រង់របស់បុគ្គលិកម្នាក់ៗដែលស្តែងឡើងតាមរយៈការគិត ការបញ្ចេញយោ បល់ និងសកម្មភាពវិជ្ជមានប្រកបដោយការទទួលខុសត្រូវខ្ពស់។

**នវានុវត្តន៍** ៖ ការអភិវឌ្ឍខ្លួនឯងជាប្រចាំតាមរយៈការពិសោធន៍ជាក់ស្តែង និងការច្នៃប្រឌិតឱ្យទាន់តម្រូវ ការសង្គម និងសកលលោកដែលរីកចម្រើនឥតឈប់ឈរ។

**ការប្តេជ្ញាចិត្ត** ៖ ការតាំងចិត្តខ្ពស់ដើម្បីឈានទៅដល់ការសម្រេចចក្ខុវិស័យបេសកកម្ម និងគោល

បំណងរបស់វិទ្យាស្ថាន។

**ប្រសិទ្ធផល** ៖សមិទ្ធផលការងារដែលសម្រេចបានប្រកបដោយគុណភាពប្រសិទ្ធភាពនិងចំណោញពេលវេលាធនធានឬថាមពល។

**៤.២.៤គោលដៅ**ក្នុងផែនការយុទ្ធសាស្ត្រ៥ឆ្នាំវិទ្យាស្ថានគរុកោលសល្យមានផែនការសម្រេច គោលដៅ ចំនួន១០ដូចខាងក្រោម៖

**គោលដៅទី១៖** ជានាអភិបាលកិច្ច ការដឹកនាំ និងការគ្រប់គ្រងល្អ

**គោលដៅទី២៖** ជានាឱ្យមានគ្រូឧទ្ទេស ដែលមានគុណវុឌ្ឍទាបបំផុតត្រឹមបរិញ្ញាបត្រជាន់ខ្ពស់

**គោលដៅទី៣៖** ជានាក្របខណ្ឌកម្មវិធីសិក្សានិងកម្មវិធីសិក្សាលម្អិតឆ្លើយតបតាមតម្រូវការសង្គម និង សកល លោក។

**គោលដៅទី៤៖** ជានាបានបរិស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព

**គោលដៅទី៥** ជម្រុញការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ដោយមានសង្គតិភាពនិងការអភិវឌ្ឍវិជ្ជាជីវៈជា ប្រចាំ (CPD)ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន(TPAP) និងគន្លងអា ជីពគ្រូបង្រៀន។

**គោលដៅទី៦** ជានាប្រព័ន្ធជានាគុណភាពផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព

**គោលដៅទី៧** ជានាឱ្យមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធជាតិ តំបន់ និងអន្តរជាតិ

**គោលដៅទី៨** ជានាឱ្យមានវប្បធម៌ស្រាវជ្រាវអប់រំក្នុងវិទ្យាស្ថាន

**គោលដៅទី៩** ជានាការធ្វើវិក្រឹតការគ្រូបង្រៀនបឋមសិក្សា និងកម្រិតមូលដ្ឋានប្រកបដោយគុណភាព

**គោលដៅទី១០** ជានាការផ្សព្វផ្សាយស្នាដៃអប់រំប្រចាំឆ្នាំ

## ៤.៣ យុទ្ធសាស្ត្រ និងសកម្មភាព

### ៤.៣.១ អភិបាលកិច្ច ការដឹកនាំ និងការគ្រប់គ្រង

**យុទ្ធសាស្ត្រទី១៖** បង្កើតរចនាសម្ព័ន្ធរបស់វិទ្យាស្ថានគរុកោសល្យឱ្យបានច្បាស់លាស់

*សកម្មភាព៖*

១. បង្កើតក្រុមប្រឹក្សាបច្ចេកទេសរបស់វិទ្យាស្ថាន និងកំណត់ពីតួនាទីភារកិច្ច

២.បង្កើតក្រុមប្រឹក្សាសិក្សាធិការ និងគណៈកម្មការនានា ក្នុងវិទ្យាស្ថាន និងកំណត់ពីតួនាទីភារកិច្ច

៣.តែងតាំងនិងកំណត់តួនាទីភារកិច្ចរបស់មន្ត្រីអប់រំនៃវិទ្យាស្ថានគរុកោសល្យ ស្របតាមប្រកាសលេខៈ៤៤៨ អយក.ប្រក និងលេខៈ៤៤៩អយក.ប្រករបស់ក្រសួងអប់រំយុវជន និងកីឡា។

**យុទ្ធសាស្ត្រទី២៖** ជម្រុញការប្រតិបត្តិប្រកបដោយគុណភាព និងប្រសិទ្ធភាព

*សកម្មភាព៖*

៤. រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ

៥. រៀបចំចងក្រងសៀវភៅព័ត៌មានរបស់មន្ត្រីអប់រំទាំងអស់ក្នុងវិទ្យាស្ថាន

៦. រៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងប្រតិបត្តិនៅក្នុងវិទ្យាស្ថាន

៧. រៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងវិទ្យាស្ថាន

៨. តាមដាន និងវាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ (ពាក់កណ្តាលឆ្នាំ និងចុងឆ្នាំ)

៩.ពិនិត្យឡើងវិញលើការអនុវត្តផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថាននៅពាក់កណ្តាលអាណត្តិ និងចុង អាណត្តិ ។

### ៤.៣.២ ធនធានគ្រូឧទ្ទេស

**យុទ្ធសាស្ត្រទី៣៖** បង្កើនចំនួនឧទ្ទេសដែលមានគុណវុឌ្ឍកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ឬបណ្ឌិតត្រូវឯកទេស បង្រៀន។

*សកម្មភាព៖*

១០.ជ្រើសរើសគ្រូឧទ្ទេសថ្មីដែលមានគុណវុឌ្ឍបរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិតនិងមានសមត្ថភាពស្រប ជំនាញ ឯកទេសច្បាស់លាស់។

១១.ជម្រុញនិងលើកទឹកចិត្តគ្រូឧទ្ទេសដែលមានស្រាប់ឱ្យបន្តការសិក្សា ដើម្បីទទួលបានគុណវុឌ្ឍកម្រិត ជាន់ខ្ពស់ ឬបណ្ឌិតស្របជំនាញឯកទេស។

១២.ស្វែងរកអាហារូបករណ៍សម្រាប់គ្រូឧទ្ទេសឱ្យបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់

បណ្ឌិតនៅ តាមគ្រឹះស្ថានឧត្តមសិក្សាក្នុង និងក្រៅប្រទេស។

### ៤.៣.៣ កម្មវិធីអប់រំ

**យុទ្ធសាស្ត្រទី៤៖** បច្ចុប្បន្នភាពលើក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ( ១២+៤ )

*សកម្មភាព៖*

១៣. បង្កើតគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សាក្នុងវិទ្យាស្ថាន

១៤.រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកចូលរួមពីនាយកដ្ឋានពាក់ព័ន្ធនឹងដៃគូអភិវឌ្ឍនានា

១៥. ផ្សព្វផ្សាយក្របខណ្ឌកម្មវិធីអប់រំទៅដល់បុគ្គលិកក្នុងវិទ្យាស្ថាន។

**យុទ្ធសាស្ត្រទី៥៖** អភិវឌ្ឍកម្មវិធីសិក្សាលម្អិតសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ ( ១២+៤ )

*សកម្មភាព៖*

១៦. បង្កើតគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សាលម្អិត

១៧. រៀបចំកម្មវិធីសិក្សាលម្អិតឱ្យឆ្លើយតបទៅនឹងក្របខណ្ឌកម្មវិធីអប់រំសម្រាប់ឆ្នាំសិក្សានីមួយៗ

**យុទ្ធសាស្ត្រទី៦៖** ជម្រុញការអនុវត្តក្របខណ្ឌកម្មវិធីអប់រំ និងកម្មវិធីសិក្សាលម្អិតឱ្យមានគុណភាព និងប្រសិទ្ធភាព

*សកម្មភាព៖*

១៨. សិក្ខាសាលាតម្រង់ទិសគ្រូឧទ្ទេសស្តីពីការអនុវត្តកម្មវិធីសិក្សាលម្អិត

១៩. ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសិក្សាលម្អិតនៅក្នុងវិទ្យាស្ថានគរុកោសល្យ

២០.រៀបចំលក្ខខណ្ឌនីតិវិធីនិងដំណើរការប្រឡងជ្រើសរើសគរុនិស្សិតចូលរៀននិងប្រឡងបញ្ចប់ការ សិក្សា

**យុទ្ធសាស្ត្រទី៧៖** ជម្រុញការអនុវត្តកម្មសិក្សាគរុកោសល្យប្រកបដោយគុណភាព និងប្រសិទ្ធភាព

*សកម្មភាព៖*

២១. រៀបចំ និងបោះពុម្ពសៀវភៅណែនាំកម្មសិក្សាគរុកោសល្យ

២២. ចុះកិច្ចព្រមព្រៀងជាមួយសាលាសហការ ស្តីពីការចុះកម្មសិក្សាគរុកោសល្យរបស់គរុនិស្សិត

២៣.ផ្សព្វផ្សាយសៀវភៅណែនាំកម្មសិក្សាគរុកោសល្យដល់បុគ្គលិកអប់រំគរុនិស្សិត នាយកសាលា និងគ្រូ បង្រៀននៅសាលាអនុវត្ត និងសាលាសហការនានា។

២៤. ពិនិត្យតាមដាន និងវាយតម្លៃ និងប្រជុំបូកសរុបការអនុវត្តកម្មសិក្សាគរុកោសល្យ។

### ៤.៣.៤ បរិស្ថានសិក្សា

**យុទ្ធសាស្ត្រទី៨៖** អភិវឌ្ឍធនធានសិក្សាដើម្បីគាំទ្រការរៀន និងបង្រៀនឱ្យមានប្រសិទ្ធភាព

*សកម្មភាព៖*

២៥. បង្កើតបណ្ណាល័យ និងបំពាក់សម្ភារស្របតាមកម្មវិធីអប់រំ

២៦.បង្កើតបន្ទប់ពិសោធន៍វិទ្យាសាស្ត្របន្ទប់សោតទស្សន៍បន្ទប់កុំព្យូទ័របន្ទប់សិល្បៈ និងបន្ទប់រោងជាង-គេហកិច្ច ដែលមានបំពាក់សម្ភារស្របតាមកម្មវិធីអប់រំ។

២៧. បង្កើតសួនបំណិនជីវិតស្របតាមកម្មវិធីអប់រំ។

**យុទ្ធសាស្ត្រទី៩៖** អភិវឌ្ឍធនធានរូបវន្ត ដើម្បីគាំទ្រប្រសិទ្ធភាពនៃការរៀន និងបង្រៀន

*សកម្មភាព៖*

២៨. រៀបចំផែនទីវិទ្យាស្ថាន និងប្លង់សាងសង់

២៩. កែលម្អទីធ្លាសម្រាប់គរុនិស្សិត

៣០. កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងវិទ្យាស្ថាន។

**យុទ្ធសាស្ត្រទី១០៖** បង្កើតសេវាគរុនិស្សិត ដើម្បីគាំទ្រការសិក្សាប្រកបដោយភាពកក់ក្តៅ និងទំនុកចិត្ត

*សកម្មភាព៖*

៣១. បង្កើតគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សាគរុនិស្សិត

៣២. ណែនាំ និងតម្រង់ទិសគរុនិស្សិតស្តីអំពីសេវាគរុនិស្សិត

៣៣. ផ្តល់សេវាគាំទ្រលើផ្នែកសិក្សា ប្រឹក្សាអាជីព និងសុខភាពដល់គរុនិស្សិត

### ៤.៣.៥ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

**យុទ្ធសាស្ត្រទី១១៖** បង្កើតកម្មវិធីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈដល់បុគ្គលិកអប់រំ

*សកម្មភាព៖*

៣៤. រៀបចំគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

៣៥. សិក្ខាសាលាពិគ្រោះយោបល់លើគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

៣៦. បោះពុម្ព និងផ្សព្វផ្សាយសៀវភៅគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

៣៧. អនុវត្តកម្មវិធីបំប៉នសមត្ថភាពវិជ្ជាជីវៈដល់គ្រូឧទ្ទេសរបស់វិទ្យាស្ថាន

៣៨. ពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធីបំប៉នសមត្ថភាពវិជ្ជាជីវៈ។

### ៤.៣.៦ ការធានាគុណភាពផ្ទៃក្នុង

**យុទ្ធសាស្ត្រទី១២៖** បង្កើតប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង

*សកម្មភាព៖*

៣៩.រៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងផ្អែកលើក្របខណ្ឌគុណវុឌ្ឍជាតិ និង ស្តង់ដារ ទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា (ACC) ។

៤០. រៀបចំ និងសិក្ខាសាលាពិគ្រោះយោបល់ឧបករណ៍វាយតម្លៃការធានាគុណភាពអប់រំផ្ទៃក្នុង

៤១. សិក្ខាសាលាពិគ្រោះយោបល់ឧបករណ៍វាយតម្លៃការធានាគុណភាពអប់រំផ្ទៃក្នុង

៤២. តាមដាន និងវាយតម្លៃការធានាគុណភាពអប់រំ។

### ៤.៣.៧ កិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ

**យុទ្ធសាស្ត្រទី១៣៖**លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នពាក់ព័ន្ធជាតិក្នុងតំបន់និង អន្តរជាតិ

៤៣. រៀបចំយន្តការទំនាក់ទំនង និងកៀងគរការចូលរួមរបស់ស្ថាប័នជាតិតំបន់ និងអន្តរជាតិ

៤៤.បង្កើតឱ្យមានកម្មវិធីទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍និងសន្និសិទនានាសម្រាប់

បុគ្គលិក អប់រំ និងគុរុនិស្សិត។

៤៥. បង្កើតគេហទំព័រទំនាក់ទំនង និងផ្សព្វផ្សាយសកម្មភាពនានារបស់វិទ្យាស្ថាន។

### ៤.៣.៨ ការស្រាវជ្រាវអប់រំ

**យុទ្ធសាស្ត្រទី១៤៖** លើកទឹកចិត្តដល់បុគ្គលិកអប់រំដើម្បីការស្រាវជ្រាវអប់រំលើការរៀន និងបង្រៀន

*សកម្មភាព៖*

៤៦. រៀបចំគោលការណ៍លើកទឹកចិត្តក្នុងការលើកកម្ពស់វប្បធម៌ស្រាវជ្រាវអប់រំ

៤៧. បង្កើតឱ្យមានសកម្មភាពស្រាវជ្រាវអប់រំសម្រាប់បុគ្គលិកអប់រំក្នុងវិទ្យាស្ថាន

៤៨. សហការជាមួយស្ថាប័នពាក់ព័ន្ធនានាលើកិច្ចការស្រាវជ្រាវអប់រំ

៤៩.ផ្តល់ឱកាសដល់ក្រុមការងារស្រាវជ្រាវអប់រំធ្វើបទបង្ហាញ និងបោះពុម្ពផ្សាយពីលទ្ធផល

ស្រាវជ្រាវ អប់រំក្នុងសន្និសិទ្ធថ្នាក់ជាតិតំបន់និងអន្តរជាតិ។

### ៤.៣.៩ ការងារវិក្រឹតការគ្រូបង្រៀន

**យុទ្ធសាស្ត្រទី១៥៖**បង្កើតកម្មវិធីវិក្រឹតការដល់គ្រូបង្រៀនកម្រិតបឋមសិក្សា និងគ្រូកម្រិតមធ្យម

សិក្សា បឋមភូមិ។

*សកម្មភាព៖*

៥០. សិក្សា និងកំណត់តម្រូវការចាំបាច់ ដើម្បីធ្វើការវិក្រឹតការគ្រូបង្រៀន

៥១. រៀបចំ និងពិគ្រោះយោបល់លើកម្មវិធីវិក្រឹតការគ្រូបង្រៀន

៥២. អនុវត្តដំណើរការវិក្រឹតការកម្មវិធីវិក្រឹតការគ្រូបង្រៀន

### ៤.៣.១០ ការផ្សព្វផ្សាយស្នាដៃអប់រំ

**យុទ្ធសាស្ត្រទី១៦៖** លើកកម្ពស់ការផលិត និងផ្សព្វផ្សាយឯកសារស្នាដៃអប់រំ

*សកម្មភាព៖*

៥៣. និពន្ធ និងរៀបចំចងក្រងឯកសារស្នាដៃអប់រំផ្សេងៗរបស់វិទ្យាស្ថាន

៥៤. បោះពុម្ព និងផ្សព្វផ្សាយឯកសារស្នាដៃអប់រំដល់សហគមន៍រៀន និងបង្រៀន។

## ៤.៤ លទ្ធផលនៃការស្រាវជ្រាវ

ការបង្ហាញលទ្ធផលជាបន្តបន្ទាប់នៅកម្រងសំណួរស្រាវជ្រាវនីមួយៗដូចខាងក្រោម៖

### ៤.៤.១:តារាងស្តីអំពីប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀន IBL

| ល.រ | សំណួរ | នាយក | គ្រូ | សិស្ស | សរុប | មធ្យមភាគ |
|---|---|---|---|---|---|---|
| 1 | ការសិក្សាស្វែងយល់ | 100.00 | 89.50 | 93.30 | 282.80 | 94.27 |
| 2 | ភាពពេញចិត្ត | 66.00 | 90.00 | 83.00 | 239.00 | 79.67 |
| 3 | ការប្រើប្រាស់ | 100.00 | 55.00 | 68.90 | 223.90 | 74.63 |
| 4 | ការពិនិត្យ តាមដាន វាយតម្លៃ | 66.70 | 40.00 | 64.20 | 170.90 | 56.97 |
| 5 | បណ្តុះអ្នកវិទ្យាសាស្ត្រ | 100.00 | 95.00 | 88.70 | 283.70 | 94.57 |
| 6 | បណ្តុះអ្នកផលិតនៅពេលអនាគត | 100.00 | 75.00 | 67.00 | 242.00 | 80.67 |
| 7 | អាចប្តូរសេដ្ឋកិច្ចមធ្យមកម្រិតទាបទៅមធ្យមកម្រិតខ្ពស់ | 100.00 | 55.00 | 61.30 | 216.30 | 72.10 |

### ៤.៤.២:ក្រាបសរសេរស្តីពីការសិក្សាស្វែងយល់ពីវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក




* 1: គណៈគ្រប់គ្រង , 2: គ្រូឧទ្ទេស , 3: គរុនិស្សិត , 4: ការបូកសរុប

ចំពោះការសិក្សាស្វែងយល់អំពីវិធីសាស្ត្រIBL នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង(94.27%)ពីសំណាក គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុនិស្សិតដែលកំពុងសិក្សាក្នុងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុនិស្សិតបានឯកភាពគ្នាទាំងស្រុងក្នុងការសិក្សាស្វែងយល់ពីវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBL។

### ៤.៤.៣:ក្រាបសរសេរស្តីពីការពេញចិត្តវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBL




* 1: គណៈគ្រប់គ្រង , 2: គ្រូឧទ្ទេស , 3: គរុនិស្សិត , 4: ការបូកសរុប

សម្រាប់ភាពពេញចិត្តក្នុងការប្រើប្រាស់IBL នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានលក្ខណៈល្អប្រសើរទាំងគណៈនាយក គ្រូឧទ្ទេស និងគរុនិស្សិតដែលកំពុងសិក្សាសរុបបាន(79,67%) ។ ចំពោះគណៈគ្រប់គ្រង មានការពេញចិត្តកម្រិតមធ្យមនៅចំពោះការពេញចិត្តរបស់គ្រូនិងគរុនិស្សិតក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកខ្ពស់យ៉ាងណាក៏ដោយ។

**៤.៤.៤:ក្រាបសរសេរស្តីពីការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBL**




* 1: គណៈគ្រប់គ្រង , 2: គ្រូឧទ្ទេស , 3: គរុនិស្សិត , 4: ការបូកសរុប

នៅក្នុងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានការប្រើប្រាស់វិធីសាស្ត្រIBL បានល្អបង្គួរ (74,63%) សម្រាប់សមត្ថភាពរបស់គណៈគ្រប់គ្រងក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក IBLមានកម្រិតខ្ពស់ តែការប្រើប្រាស់របស់គ្រូឧទេសវិញនៅមានកម្រិតត្រឹមមធ្យមក៏ព្រោះតែសមត្ថភាពយល់ដឹងមិនទាន់បានច្បាស់លាស់និងស៊ីជម្រៅ ដែលជាហេតុនាំឲ្យការប្រើប្រាស់របស់គរុនិស្សតក៏មិនទាន់មានលក្ខណៈល្អប្រសើរ។

**៤.៤.៥:ក្រាបសរសេរស្តីពីការពិនិត្យតាមដានវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBL**




* 1: គណៈគ្រប់គ្រង , 2: គ្រូឧទ្ទេស , 3: គរុនិស្សិត , 4: ការបូកសរុប

នៅក្នុងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានធ្វើការត្រួតពិនិត្យ តាមដាននិងវាយតម្លៃអំពីការប្រើប្រាស់វិធីសាស្ត្រIBL នៅត្រឹមកម្រឹតមធ្យមនៅឡើយ(56,97%)។ សម្រាប់ការត្រួតពិនិត្យ តាមដាននិងកែលម្អអំពីវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBL របស់គណៈគ្រប់គ្រងនៅមានកម្រិតមធ្យម តែសម្រាប់ការត្រួតពិនិត្យតាមដាននិងកែលម្អរបស់គ្រូមានកម្រិតខ្សោយ អាចបណ្តាលមកពីសមត្ថភាពនៃការស្វែងយល់ពីវិធីសាស្ត្រIBL។

### ៤.៤.៦:ក្រាបសរសេរស្តីពីវិធីសាស្ត្រIBLអាចបណ្តុះអ្នកវិទ្យាសាស្ត្រវ័យក្មេង




* 1: គណៈគ្រប់គ្រង , 2: គ្រូឧទ្ទេស , 3: គរុនិស្សិត , 4: ការបូកសរុប

នៅក្នុងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញពេញបានយល់ឃើញថា ការប្រើប្រាស់វិធីសាស្ត្រ IBL អាចបណ្តុះអ្នកវិទ្យាសាស្ត្រវ័យក្មេង បានល្អប្រសើរណាស់(94,57%)។ វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក គឺជាវិធីសាស្ត្រមួយដែលមានសារៈសំខាន់ណាស់សម្រាប់ការបណ្តុះបណ្តាលអ្នកវិទ្យាសាស្ត្រវ័យក្មេង ទាំងនេះគឺជាការឯកភាពយល់ឃើញរបស់គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុនិស្សិត។

### ៤.៤.៧:ក្រាបសរសេរស្តីពីវិធីសាស្ត្រIBLអាចបណ្តុះអ្នកផលិតនៅពេលអនាគត




* 1: គណៈគ្រប់គ្រង , 2: គ្រូឧទ្ទេស , 3: គរុនិស្សិត , 4: ការបូកសរុប

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញយល់ឃើញថាIBL អាចធ្វើពលរដ្ឋខ្មែរក្លាយជាអ្នកផលិតនៅពេលអនាគតបានល្អ(80,67%)។ ការបណ្តុះអ្នកផលិត នៅកម្ពុជានាពេលអនាគត វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកគឺប្រាកដជាអាចជួយបាន នេះបើតាមការយល់ឃើញពីសំណាកគណៈគ្រប់គ្រង គ្រូឧទ្ទេស និង គរុនិស្សិតនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

### ៤.៤.៣:ក្រាបសរសេរស្តីពីវិធីសាស្ត្រIBLអាចប្តូរសេដ្ឋកិច្ចមធ្យមកម្រិតទាបទៅខ្ពស់




* 1: គណៈគ្រប់គ្រង , 2: គ្រូឧទ្ទេស , 3: គរុនិស្សិត , 4: ការបូកសរុប

សម្រាប់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBL វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញបានយល់ឃើញកម្រិតល្អបង្គួរ( 72,10% ) ក្នុងការផ្លាស់ប្តូរសេដ្ឋកិច្ចជាតិពីមធ្យមកម្រិតទាប ក្លាយជាសេដ្ឋកិច្ចមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ខាងមុខ។

## ៤.៥.ការវិភាគបែបយុទ្ធសាស្ត្រ

### ៤.៥.១ ចំណុចខ្លាំង

- វិទ្យាស្ថានគរុកោលស្យរាជាធានីភ្នំពេញ ជាវិទ្យាស្ថានមួយដែលត្រូវគេបង្កើតឡើងពីការបញ្ចូលគ្នាពីអតីតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យនិងវិក្រិតការរាជធានីភ្នំពេញ ដែលមានប្រវត្តិសាស្ត្រយូរអង្វែង និងមានបទពិសោធន៍ក្នុងការបណ្តុះបណ្តាលគ្រូកម្រិតបឋមសិក្សា និងកម្រិតគ្រូមធ្យមសិក្សា( អនុវិទ្យាល័យ )និងធ្វើវិក្រិតការគ្រូបង្រៀនក្នុងប្រទេសកម្ពុជា។

- ទាំងអតីតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគភ្នំពេញ សាលាគរុកោសល្យនិងវិក្រិតការរាជធានីភ្នំពេញសុទ្ធតែមានបុគ្គលិក គ្រូឧទ្ទេស មួយចំនួនដែលមានសក្តានុពលក្នុងការកែលម្អគុណភាពអប់រំនៅវិទ្យាស្ថានគរុកោសល្យ

- គណៈគ្រប់គ្រង ថ្នាក់ដឹកនាំវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ កកើតពីការប្រឡងប្រកួតប្រជែងសមត្ថ

ភាពខ្ពស់ ដែលយកចិត្តទុកដាក់ខ្ពស់គណៈកម្មការ និងថ្នាក់ដឹកនាំក្រសួងអប់រំយុវជននិងកីឡា។

- លក្ខខណ្ឌក្នុងការជ្រើសរើសគ្រូឧទ្ទេសថ្មីៗ ត្រូវបានកំណត់យ៉ាងត្រឹមត្រូវ ច្បាស់លាស់ដែលអាចឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

- វិទ្យាស្ថានគរុកោសល្យមានដៃគូអភិវឌ្ឍច្រើនទាំងជាតិនិងអន្តរជាតិ ជាពិសេសមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាកថ្នាក់ដឹកនាំក្រសួងអបរំយុវជននិងកីឡា។

- វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ មានលិខិតបទដ្ឋានគតិយុត្តច្បាស់លាស់ និងមានចរនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវទៅតាមតួនាទីនិងភារកិច្ចច្បាស់លាស់។

- វិទ្យាស្ថានគរុកោល្យរាជធានីភ្នំពេញ មានបរិវេណធំទូលាយ និងមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។

- វិទ្យាស្ថានគរុកោសល្យ មានអគារសិក្សា សាលប្រជុំ បន្ទប់ពិសោធ បន្ទប់ការិយាល័យផ្សេងៗ អន្តេវសិកដ្ឋានសម្រាប់គរុនិស្សិតស្នាក់អាស្រ័យនិងសិក្សាបានល្អប្រសើរ

### ៤.៥.២ ចំណុចខ្សោយ

–ដោយសារតែវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ជាវិទ្យាស្ថានថ្មីហើយវិទ្យាស្ថាននេះត្រូវកសាងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀតក្នុងការបង្កើតកិច្ចប្រតិបត្តិការ វិទ្យាស្ថានដែលផ្តល់កម្មវិធីបណ្តុះបណ្តាលរយៈពេល ៤ឆ្នាំ សមមូលនឹងកម្រិតបរិញ្ញាបត្រក្នុងប្រទេសកម្ពុជា ឱ្យប្រព្រឹត្តទៅបានដោយរលូន។

–វិទ្យាស្ថាននេះមានកង្វះខាតធនធានមនុស្សដើម្បីអនុវត្តទៅតាមតួនាទី និងភារកិច្ច ដែលបានកំណត់ក្នុង លិខិតបទដ្ឋានគតិយុត្ត។

–សមត្ថភាពរបស់គ្រូឧទ្ទេសមួយចំនួនដែលមានស្រាប់នៅមានកម្រិតពីព្រោះពួកគាត់មានកម្រិតវប្បធម៌ត្រឹម តែបរិញ្ញាបត្រគ្រូឧទ្ទេសតែ១២,៥%ប៉ុណ្ណោះមានបរិញ្ញាបត្រជាន់ខ្ពស់ត្រូវមុខវិជ្ជាឯកទេសនិងពុំមាន គ្រូឧទ្ទេស ដែលមាន សញ្ញាបត្របណ្ឌិតឡើយ។

– ធនធានរៀន និងបង្រៀន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌ

– កម្មវិធីសិក្សាតាមមុខវិជ្ជា និងខ្លឹមសារមេរៀនពុំមានការអភិវឌ្ឍកិច្ចសហការជាមួយស្ថាប័នជាតិ

និងអន្តរជាតិមានភាពទន់ខ្សោយនៅឡើយ

– បុគ្គលិកអប់រំទាំងអស់នៅមានកម្រិតលើបទពិសោធន៍ស្រាវជ្រាវ

– ពុំមានកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ

– ពុំមានប្រព័ន្ធធានាគុណភាពផ្ទៃក្នុងដើម្បីធានាប្រតិបត្តិការ និងគុណភាពអប់រំប្រកបដោយប្រសិទ្ធភាព

– វិទ្យាស្ថានរងនូវគ្រោះទឹកជំនន់នៅរដូវវស្សា

– ធនធានថវិកាសម្រាប់ប្រតិបត្តិការនៅក្នុងវិទ្យាស្ថាននៅមានកម្រិត

– កង្វះខាតគ្រូឧទ្ទេសដែលមានសមត្ថភាពនិងបទពិសោធន៍លើការងារស្រាវជ្រាវ ដើម្បីជម្រុញការស្រាវ ជ្រាវនៅក្នុងវិទ្យាស្ថាននាពេលខាងមុខ

– កង្វះខាតគ្រូឧទ្ទេសដែលមានសមត្ថភាពក្នុងការផ្តល់នូវមុខវិជ្ជាឯកទេស។

សរុបជារួមមក វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញពិតជាអាចបណ្តុះបណ្តាលគរុនិស្សិតឲ្យក្លាយទៅជាគ្រូដែលមានសមត្ថភាព សកម្មនិងឆ្នើមក្នុងសតវត្សទី២១ ទៅតាមឯកទេសនិងជំនាញរបស់ខ្លួន ក៏ព្រោះតែការប្រើប្រាស់វិធីសាស្ត្របង្រៀនចំរុះជាពិសេសវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBL។ ក្នុងចំណុចនេះដែរគ្រូឧទ្ទេសគួរតែយកចិត្តទុកដាក់និងព្យាយាមប្រើប្រាស់វិធីសាស្ត្រIBLឲ្យបានសកម្មនិងច្បាស់លាស់ ជាពិសេសការពិនិត្យតាមដាននិងការត្រួតពិនិត្យកែលម្អ វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកIBLនៅមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេ។

### ៤.៥.៣ ភាពឱកាស

–ក្រសួងអប់រំយុវជននិងកីឡា បានផ្តល់អាទិភាពខ្ពស់ដល់វិទ្យាស្ថានគរុកោសល្យក្នុងការលើកកម្ពស់គុណ ភាពអប់រំដែលមាននៅក្នុងគោលនយោបាយកំណែទម្រង់ ដែលអនុម័តកម្មវិធីបណ្តុះបណ្តាលតាម

រូបមន្ត ១២+៤។

– មានសិស្សជាច្រើនដាក់ពាក្យប្រឡងចូលរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុ កោសល្យ និងរឹក្រឹតការរៀងរាល់ឆ្នាំ។

– មានការគាំទ្រទាំងផ្នែកបច្ចេកទេសនិងរដ្ឋបាលពីនាយកដ្ឋានពាក់ព័ន្ធថ្នាក់ជាតិតាមរយៈគណៈកម្មការ អភិវឌ្ឍគ្រូបង្រៀន។

– អង្គការJICAគឺជាអ្នកគាំទ្រលើផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុសម្រាប់ការបង្កើតវិទ្យាស្ថានគរុកោសល្យ

– មានស្ថាប័ន និងដៃគូអភិវឌ្ឍនានា (អង្គការ VVOB អង្គការ VSO សាកលវិទ្យាល័យ Hiroshima និងស្ថាប័នដទៃទៀត។

**៤.៥.៤ កត្តាប្រឈម**

សកម្មភាពវិទ្យាស្ថាននឹងមិនអាចអនុវត្តបានទេ ឬមានការអោក់រអួល ករណី៖

- មិនមានថវិកាគ្រប់គ្រាន់

- ទទួលរងនូវគ្រោះមហន្តរាយដូចជាគ្រោះទឹកជំនន់ ខ្យល់ព្យុះ និងជំងឺរាតត្បាត (Covid-19)

# ជំពូកទី៥

# ការសេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី «ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រIBLនៅវិទ្យា ស្ថានគរុកោសល្យរាជធានីភ្នំពេញ(១២+៤)»ខ្ញុំបាទអាចសន្និដ្ឋានបានថា៖ កម្មវិធីបណ្តុះបណ្តាលវិទ្យាស្ថាន គរុកោសល្យរាជធានីភ្នំពេញមានគោលបំណងចម្បងមួយគឺ ផ្តល់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំតាមរូប មន្ត១២+៤ ដែលអនុវត្តពី ជំនាន់ទី១ ទៅរហូតដល់ឆ្នាំសិក្សា២០១៩-២០២០។

វិទ្យាស្ថានគរុកោសល្យរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ផែនការយុទ្ធសាស្ត្រ២០១៨-២០២៣ ដើម្បីសម្រេចចក្ខុវិស័យក្លាយជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូឈានមុខគេក្នុងសតវត្សរ៍ទី២១។ចក្ខុវិស័យ« ជាវិទ្យាស្ថានឈានមុខគេក្នុងសតវត្សទី២១» បេសកកម្មដើម្បីសម្រេចបាននូវចក្ខុវិស័យវិទ្យាស្ថានគរុកោសល្យរាជធានី ភ្នំពេញបានកំណត់បេសកកម្មចម្បងចំនួន៣គឺ៖អប់រំគរុនិស្សិត និងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យមានគុណ សម្បទាពេញលេញលើកកម្ពស់ការស្រាវជ្រាវអប់រំដើម្បីបង្កើនគុណភាពការបង្រៀននិងរៀន ផ្តល់សេវា សហគមន៍ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ គុណតម្លៃវិទ្យាស្ថានគរុកោសល្យរាជ ជានីភ្នំពេញអនុវត្តតួនាទីភារកិច្ចដោយឈរលើគុណតម្លៃជាគន្លឹះចំនួន៥គឺ ការគោរព សុចរិត នវានុវត្តន៍ ការប្តេជ្ញាចិត្ត និង ប្រសិទ្ធផល។

យុទ្ធសាស្ត្រ និងសកម្មភាព អភិបាលកិច្ច ការដឹកនាំ និងការគ្រប់គ្រង មានដូចជា៖ ធនធានគ្រូឧទ្ទេស កម្មវិធីអប់រំបរិស្ថានសិក្សាការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈការធានាគុណភាពផ្ទៃក្នុង កិច្ចសហការជាមួយស្ថាប័ន ពាក់ព័ន្ធ ការស្រាវជ្រាវអប់រំ ការងារវិក្រឹតការគ្រូបង្រៀន ការផ្សព្វផ្សាយស្នាដៃអប់រំ។

ការវិភាគបែបយុទ្ធសាស្ត្រមានចំណុចខ្លាំងវិទ្យាស្ថានរាជធានីភ្នំពេញ ជាវិទ្យាស្ថានមួយត្រូវបានគេបង្កើតឡើង ពីការបញ្ចូលគ្នាពីអតីតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញ ដែលប្រវត្តិសាស្តយូរអង្វែង និងបទពិសោធន៍ក្នុងការបណ្តុះបណ្តាលគ្រូបឋមសិក្សា និង

អនុ  វិទ្យាល័យនិងវិក្រឹតការគ្រូបង្រៀនក្នុងប្រទេសកម្ពុជា។មជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញ មានបុគ្គ លិកអប់រំ មួយចំនួនដែលមានសក្ដានុពលក្នុងការកែលម្អគុណភាពអប់រំនៅក្នុងវិទ្យាស្ថានគរុកោសល្យ។ ចំណុចខ្សោយ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញជាវិទ្យាស្ថានថ្មីហើយវិទ្យាស្ថាននេះត្រូវកសាងលិខិតបទដ្ឋានគតិយុត្ត ជា ច្រើនទៀតក្នុងការបង្កើតកិច្ចប្រតិបត្តិការវិទ្យាស្ថាន ដែលផ្ដល់កម្មវិធីបណ្ដុះបណ្ដាលរយៈពេល៤ឆ្នាំសមមូលនឹង កម្រិតបរិញ្ញាបត្រក្នុងប្រទេសកម្ពុជាឱ្យប្រព្រឹត្តទៅបានដោយរលូន។ វិទ្យាស្ថាននេះមានកង្វះខាតធនធានមនុស្ស ដើម្បីអនុវត្តទៅតាមតួនាទីនិងភារកិច្ចដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្ត។កាលានុវត្តភាព ក្រសួងអប់រំ យុវជននិងកីឡាបានផ្ដល់អាទិភាពខ្ពស់ដល់វិទ្យាស្ថានគរុកោសល្យក្នុងការលើកកម្ពស់គុណភាពអប់រំដែលមាននៅក្នុងគោលនយោបាយកំណែទម្រង់ដែលអនុម័តកម្មវិធីបណ្ដុះបណ្ដាលតាមរូបមន្ត ១២+ ៤ ។ កត្តាប្រឈមសកម្មភាពវិទ្យាស្ថាននឹងមិនអាចអនុវត្តបានទេឬមានការអោក់រអួលករណីៈ មិនមានថវិកាគ្រប់គ្រាន់ និងទទួលរងនូវគ្រោះមហន្តរាយដូចជាគ្រោះទឹកជំនន់ និងខ្យល់ព្យុះ។

សរុបសេចក្ដីមកការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ស្ដីពី «ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រ IBL នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(១២+៤)» ឃើញថាការប្រើប្រាស់វិធីសាស្ត្រIBLមានប្រសិទ្ធខ្ពស់សម្រាប់តម្រូវការចាំបាច់នៅក្នុងវិស័យអប់រំណាស់ ជាពិសេសសម្រាប់គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញទាំងគ្រូឧទ្ទេសនិងគរុនិស្សិត។

ជាមួយគ្នានេះដែរប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក IBL មានបញ្ហាប្រឈមសំខាន់មួយគឺកង្វះខាតផ្នែកត្រួតពិនិត្យតាមដាននិងកែលម្អដែលជាហេតុនាំមានការប្រើប្រាស់វិធីសាស្ត្រមួយនេះរបស់គ្រូឧទ្ទេសនិងគរុនិស្សិតនៅពុំទានមានលក្ខណៈល្អប្រសើរនៅឡើយ

## ៥.២ សំណូមពរ

ដោយផ្អែកទៅលើការសិក្សាស្រាវជ្រាវលើប្រធានបទស្ដីពី « ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រ IBL នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(១២+៤)»នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានបង្ហាញឡើងឱ្យឃើញនូវចំណុចល្អៗនិងលក្ខណៈពិសេសជាច្រើនរបស់វិទ្យាស្ថានប៉ុន្តែទន្ទឹមគ្នានោះដែរក៏

មានចំណុចខ្វះខាតមួយចំនួនផងដែរ។ ទាំងនេះគឺជាចំណុចកែលម្អទៅលើចំណុចខ្វះខាតមួយចំនួនដែលការសិក្សាស្រាវជ្រាវបានរកឃើញនិងសូមផ្តល់ជាយោបល់ខ្លះៗទៅតាមការយល់ឃើញបន្ទាប់ពីបានសិក្សាស្រាវជ្រាវដែលរួមមាន៖

– វិទ្យាស្ថានគួរបន្ថែមនូវធនធានមនុស្សផ្នែកគ្រូឧទ្ទេសឱ្យត្រូវជំនាញទៅតាមមុខវិជ្ជាដែលបណ្តុះបណ្តាលគរុនិស្សិតជាក់ស្តែងបន្ថែមទៀត ដើម្បីបំពេញនៅតម្រូវការរបស់សង្គមនិងការអភិវឌ្ឍចំណេះដឹងផ្នែកជំនាញប្រកបដោយប្រសិទ្ធភាព។

–វិទ្យាស្ថានគួរពង្រឹងផ្នែកបណ្តុះបណ្តាលវិធីសាស្ត្រ IBL នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (១២+៤)ឱ្យបានទូលំទូលាយ ដើម្បីជាប្រយោជន៍សម្រាប់ពុទ្ធិក្នុងការអប់រំគរុនិស្សិត និងគ្រូឧទ្ទេស។

–វិទ្យាស្ថានគួរមានការត្រួតពិនិត្យតាមដាននិងវាយតម្លៃ វិធីសាស្ត្រIBLជាប្រចាំ

–គ្រូឧទ្ទេសគួរប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកឲ្យបានច្បាស់លាស់ សកម្ម។ គ្រូគួរចូលរួមធ្វើការត្រួតពិនិត្យតាមដាននិងវាយតម្លៃវិធីសាស្ត្រIBLជាមួយអ្នកបច្ចេកទេស និងគរុនិស្សិត។

# ឯកសារយោង


- វចនានុក្រមខ្មែរ. (១៩៦៧).សម្តេចសង្ឃរាជ ជួន ណាត

- វិធីសាស្ត្របង្រៀន នៅសាលាបឋមសិក្សា និងមធ្យមសិក្សា. (១៩៩៤).បូ ជុំស៊ិន

-ការប្រើប្រាស់ពាក្យគន្លឹះក្នុងវិស័យអប់រំ.(១៩៩៥).ក្រសួងអប់រំយុវជននិងកីឡា

- ប្រវត្តិក្រសួងអប់រំ. (១៩៩៨).យង់ ធី ,ស៊ន សំណាង

-ប្រវត្តវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល.(២០០២).មាឃសារី

- ច្បាប់អប់រំ.(ខែធ្នូ, ២០០៧).ក្រសួងអប់រំយុវជននិងកីឡា

-គរុកោលស្យ.(២០០៨).ពៅសាគួង

-ចិត្តវិទ្យាអប់រំ.(២០០៨).ឈួនត្រាយ,ផាន់ចាន់ពៅ

-ឯកសារបំប៉នគ្រូឧទ្ទេសសាលាគរុកោសល្យនិងវិក្រឹតការការកែលម្អកិច្ចតែងការបង្រៀន (២០០៩)ក្រសួងអប់រំយុវជននិងកីឡា

-ឯកសារបំប៉នគ្រូមធ្យមសិក្សា(២០០៩).ក្រសួងអប់រំយុវជននិងកីឡា

-ទស្សនវិជ្ជាអប់រំរបស់លោកចនដេវី(២០០៩)ហង្សកក្កដារាស្សី

- បំប៉នសមត្ថភាពគ្រូបង្រៀនកម្រិតមូលដ្ឋាន(២០១០)នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ

-កម្មវិធីសាលាកុមារមេត្រី(២០១២)ក្រសួងអប់រំយុវជននិងកីឡា

-គោលនយោបាយគ្រូបង្រៀន(២០១៣)ក្រសួងអប់រំយុវជននិងកីឡា

-ប្រព័ន្ធធានាគុណភាព(២០១៣)ក្រសួងអប់រំយុវជននិងកីឡា

-ស្វ័យវាយតម្លៃសាលា(២០១៤)ក្រសួងអប់រំយុវជននិងកីឡាផ

-ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨(២០១៤)ក្រសួងអប់រំយុវជននិងកីឡា

-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(២០១៤-២០១៨)រាជរដ្ឋាភិបាលកម្ពុជា

-គោលនយោបាយស្តីពីគ្រូបង្រៀន(២០១៥)ក្រសួងអប់រំយុវជននិងកីឡា

-គោលនយោបាយស្តីពីផែនការសកម្មភាព(២០១៥)ក្រសួងអប់រំយុវជននិងកីឡា

-ចក្ខុវិស័យនៃកំណែទម្រង់នៅកម្ពុជា(២០១៥)ហង់ជួនណារ៉ុន

-គរុកោសល្យ(២០១៥)នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ

- ស្តង់ដាបណ្តុះបណ្តាលគ្រូបង្រៀន(២០១៥) ក្រសួងអប់រំយុវជនិងកីឡា

- ក្របខណ្ឌសម្រាប់សកម្មភាពវិស័យអប់រំឆ្នាំ២០៣០ សេចក្តីប្រកាស់នៅទីក្រុងអ៊ីន ឈុន (២០១៥)ក្រសួងអប់រំយុវជននិងកីឡា

- គរុកោសល្យសម្រាប់បណ្តុះបណ្តាលគ្រូមធ្យមសិក្សា(២០១៥)នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
- អនុក្រឹតស្តីពីការរៀបចំនិងប្រព្រឹតទៅរបស់ក្រសួងអប់រំយុវជននិងកីឡា(២០១៦) ក្រសួងអប់រំ យុវជន និងកីឡា
- បទបញ្ញត្តិនិងសេចក្តីណែនាំការអនុវត្តកម្មសិក្សាគរុកោសល្យ(២០១៦) ក្រសួងអប់រំ យុវជននិងកីឡា
- ការងារអធិការកិច្ចសាលារៀន(២០១៧) ក្រសួងអប់រំយុវជននិងកីឡា
- គរុកោសល្យ(២០១៧) អ៊ុំ សាខន
- វិធីសាស្ត្របង្រៀននៅឧត្តមសិក្សា(២០១៧) ង៉ាន់ ស៊ុនដេត
- ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូនៅវិទ្យាល័យ(២០១៧) ជិន ចាន់វន្នី
- ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន គណិតវិទ្យានៅមធ្យមសិក្សាទុតិយភូមិ (២០១៨) ហឿល រដ្ឋា
- ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន(២០១៨)ក្រសួងអប់រំយុវជននិងកីឡា
- ច្បាប់រដ្ឋធម្មនុញ្ញ(២០.ឧសភា.២០១៨)អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- បញ្ញត្តិជានាគុណភាពអប់រំ(២០១៨)ក្រសួងអប់រំយុវជននិងកីឡា
- ផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៩-២០២៣(២០១៨)រាជរដ្ឋាភិបាលកម្ពុជា
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣(២០១៨)ក្រសួងអប់រំយុវជននិងកីឡា
- វិធានការឆ្លើយតបលទ្ធផលPISA(២០១៨)ហង់ ជួនណារ៉ុន
- វិធីសាស្ត្របង្រៀន(២០១៩)ប្រាក់ ពៅ, ឃិន វណ្ណី, បាន កក្កដា
- គោលនយោបាយជាតិ ស្តីពីការសិក្សាពេញមួយជីវិត(២០១៩)រាជរដ្ឋាភិបាលកម្ពុជា

- Alberta, (2002). Instuctional Strategies

- Lynne Hill, (2002). Professional Development Strand. Teaching Methodology

- NIE-Singapore, (2009): A teacher education mode for the 21 century

- Madrid Spain, (Nov 2011). The education in Singapore

- Khieng Sothy ,Srinivasa Madhur, Chem Rethy (May 2015): Education in Cambodia

- Izalela C.T Barbieru,(2016): Key Concepts in the Pedagogy of John Dewey

- Betha Gunnarsdottir, May (2016): Japan´s education system

- Word Vision,(2017):Introduction of teaching and Learning

# ឧបសម្ព័ន្ធ

## កម្រងសំណួរសម្រាប់គ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

ខ្ញុំបាទឈ្មោះ គង់ ពេញ ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ខ្ញុំបាទបានរៀបចំការ
ស្រាវជ្រាវលើប្រធានបទ« ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក IBL នៅវិទ្យាស្ថានគរុកោលល្យ រាជធានីភ្នំពេញ(១២+៤) » ។ អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោក លោកស្រីជាគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ មេត្តាជួយសម្រួល និងផ្តល់ទិន្នន័យជាក់ស្តែង ដោយក្តីអនុគ្រោះ។ រាល់ទិន្នន័យទាំងឡាយ ដែលមានក្នុងកម្រងសំណួរមួយនេះ ខ្ញុំបាទសូមអនុញ្ញាតប្រើសម្រាប់តែសរសេរនិក្ខេបបទតែប៉ុណ្ណោះ។ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលចំណាយពេលដ៏មានតម្លៃរបស់ខ្លួន ក្នុងការចូលរួមចែលរំលែកជាវិភាគទានដល់ការស្រាវ ជ្រាវដ៏មានសារៈសំខាន់របស់ខ្ញុំបាទមួយនេះ។

សូមអនុញ្ញាតដោយក្តីគោរព ដោយគូសសញ្ញា✓ ក្នុងប្រអប់ និងបំពេញចន្លោះតាមភាពជាក់ស្តែង

ផ្នែកទី១: ព័ត៌មានទូទៅ

១. ភេទ ស្រី ប្រុស

២. តួនាទី/ ឋានៈ គ្រូឧទ្ទេស គ្រូឧទ្ទេសរង គ្រូឧទ្ទេសជំនួយ

៣. អាយុ ក្រោម៣០ឆ្នាំ លើស៣០ឆ្នាំ

៤. ឯកទេសៈ ……………………………………….

៥. មុខវិជ្ជាបង្រៀនៈ…………………………………

ផ្នែកទី២: គុណវុឌ្ឍិ

៦. តើលោក លោកស្រី មានក្របខណ្ឌប្រភេទអ្វី?

គ្រូបង្រៀនកម្រិតមូលដ្ឋាន គ្រូបង្រៀនកម្រិតឧត្តម

៧. តើលោក លោកស្រី មានបទពិសោធបង្រៀនប៉ុន្មានឆ្នាំ?

១ឆ្នាំ-៥ឆ្នាំ ៥ឆ្នាំ-១០ឆ្នាំ

១០ឆ្នាំ-១៥ឆ្នាំ ១៥ឆ្នាំឡើងទៅ

៨. តើលោក លោកស្រី ទទួលបានសញ្ញាបត្រចុងក្រោយកម្រិតអ្វី?

សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សញ្ញាបត្របរិញ្ញាបត្រប(ឯកទេសៈ…………………………………………………….)

សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់(ឯកទេសៈ…………………………………………………)

សញ្ញាបត្របណ្ឌិត (ឯកទេសៈ…………………………………………………)

ផ្នែកទី៣: ចំណេះដឹងស្ដីពីវិធីសាស្ត្របង្រៀននិងរៀន IBL

៩. តើលោក លោកស្រីធ្លាប់ស្វែងយល់ពីវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក ឬទេ?

ធ្លាប់ មិនធ្លាប់(បើមិនធ្លាប់សូមរំលងទៅសំណួរទី៩)

១០. តើលោកលោកស្រីធ្លាប់សិក្សាស្វែងយល់ពីវិធីសាស្ត្របង្រៀននិងរៀនតាមរយៈអ្វី?

វគ្គបំប៉ន ការស្រាវជ្រាវ ផ្សេងៗ

១១. តើវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកមានសារៈសំខាន់សម្រាប់ការងារអ្នក ឬទេ?

មានសារៈសំខាន់ មិនមានសារៈសំខាន់

២០. តើអ្នកពេញចិត្តវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ដែរទេ?

មិនពេញចិត្ត ធម្មតា មិនពេញចិត្ត

២១. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ជាវិធីដែលគាំទ្រគោលវិធីសិស្សមជ្ឈមណ្ឌល។

មិនច្បាស់ មិនពិត ពិតណាស់

២២. វិធីសាស្ត្រ IBL គ្រូត្រូវមានភាពអត់ធ្មត់ និងជឿជាក់ថាសិស្សអាចធ្វើដោយខ្លួនឯងផ្អែកលើចំណេះមានស្រាប់។

មិនច្បាស់ មិនពិត ពិតណាស់

២៣. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក គឺពូនផ្ដុំចំណេះដឹងសិស្សមិនមែនគម្ពីនិយមឡើយ។

មិនច្បាស់ មិនពិត ពិតណាស់

២៤. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកអាចប្រើប្រាស់គ្រប់មុខវិជ្ជាសិក្សាទាំងអស់ ប្រកបដោយប្រសិទ្ធិភាព។

មិនច្បាស់ មិនពិត ពិត

២៥. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកគឺជាបង្រៀនពិសោធន៍ តែការបង្រៀនពិសោធន៍ក៏មិនប្រាកដជា IBL ដែរ។

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

២៦. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក បង្រៀនតែលំនាំវិទ្យាសាស្ត្រ មិនមែនខ្លឹមសារទេ គឺIBL ប្រើលំនាំវិទ្យាសាស្ត្រដើម្បី បង្រៀនខ្លឹមសារ ។

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

២៧.ការបង្រៀននិងរៀនតាមបែបរិះរកមានទម្រង់លក្ខណៈបែបវិទ្យាសាស្ត្រសង្គម.

មិនច្បាស់ មនត្រឹមត្រូវ ត្រឹមត្រូវណាស់

២៨. ការបង្រៀននិងរៀនតាមបែបរិះរកមានទម្រង់លក្ខលៈបែបវិទ្យាសាស្ត្រពិត

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

២៩. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកអាចបណ្ដុះគំនិតបែបអ្នកវិទ្យាសាស្ត្រដល់សិស្ស។

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

៣០. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកអាចធ្វើឲ្យពលរដ្ឋក្លាយជាអ្នកផលិតនៅពេលអនាគត

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

៣១. វិធីសាស្ត្របង្រៀននិងររៀនតាមបែបរិះរកអាចធ្វើឲ្យមានកំណើនសេចដ្ឋកិច្ចជាតិនៅឆ្នាំ២០៣០

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

ផ្នែកទី៤: ការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក

*កម្រិតចង្អុលបង្ហាញ

1= មិនច្បាស់

2= មិនយល់ស្របទាំងស្រុង

3= យល់ស្របខ្លះៗ

4= យល់ស្រប

5= យល់ស្របទាំងស្រុង

| N | បរិយាយ | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|
| 1 | ខ្ញុំដឹងថាគណៈគ្រប់គ្រងយកចិត្តទុកដាក់ខ្ពស់ចំពោះវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 2 | ខ្ញុំដឹងថាគណៈគ្រប់គ្រងពេញចិត្តនឹងវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 3 | ខ្ញុំធ្លាប់បានចូលរួមវគ្គបំប៉នវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកឲ្យ | | | | | |
| 4 | ខ្ញុំអាចប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ដោយសារមានការអនុញ្ញាតពីគណៈគ្រប់គ្រង | | | | | |
| 5 | ខ្ញុំទទួលបានទឹកចិត្តពីគណៈគ្រប់គ្រងឲ្យសិក្សាវិធីសាស្ត្រ IBL បន្ថែមនៅបរទេស | | | | | |
| 6 | ខ្ញុំបានដឹងពីកម្មវិធីពិនិត្យតាមដានវាយការប្រើប្រាស់វិធីសាស្ត្រIBL របស់គណៈគ្រប់គ្រង | | | | | |
| 7 | ខ្ញុំទទួលបានការពិនិត្យ តាមដាន និងវាយតម្លៃការប្រើប្រាស់វិធីសាស្ត្រIBL របស់គណៈគ្រប់គ្រង | | | | | |
| 8 | ខ្ញុំបានបន្តការស្រាវជ្រាវវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកជាប្រចាំបន្ថែមដើម្បីបានច្បាស់លាស់ | | | | | |
| 9 | ខ្ញុំបានចែងចែកសិស្សជាក្រុមក្នុងការរៀបចំធ្វើបទបង្ហាញខ្លឹមសារមេរៀន | | | | | |
| 10 | ខ្ញុំជាអ្នកសម្របសម្រួលក្នុងបង្កើតពាក្យគន្លឹះនៃខ្លឹមសារមេរៀនរបស់គរុនិស្សិត | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| 11 | ខ្ញុំគ្រាន់តែជាអ្នកសម្របសម្រួលឲ្យគរុនិស្សិតទាញយកសេចក្តីសន្និដ្ឋានខ្លឹមសារមេរៀន | | | | | |
| 12 | ខ្ញុំផ្តល់លទ្ធភាពឲ្យគរុនិស្សិតធ្វើការបូកសរុបសំយោគខ្លឹមសារបញ្ចប់មេរៀន | | | | | |
| 13 | ខ្ញុំបានកែលម្អចំនុចខ្វះខាតនិងការយល់ព្រមទទួលស្គាល់ចំនុចខ្វះខាតរបស់គរុនិស្សិត | | | | | |
| 14 | ខ្ញុំប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកមានលក្ខណៈរលូនជាមួយគរុនិស្សិត( មេរៀនខ្លះ ) | | | | | |
| 15 | ខ្ញុំតែងតែប្រាប់ពីវត្ថុបំណងមេរៀនទៅគរុសិស្សមុខ គ្រប់មេរៀនដែលខ្ញុំប្រើវិធីសាស្ត្រIBL | | | | | |
| 16 | ខ្ញុំតែងតែប្រាប់សិស្សឲ្យអានមេរៀននៅក្នុងដំណើរការបង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 17 | ជាទូទៅខ្ញុំប្រើប្រាស់ជំហ៊ានIBL នៅក្នុងជំហ៊ានទី៣នៃលំនាំបង្រៀនរបស់ខ្ញុំ | | | | | |
| 18 | ខ្ញុំចំណាយពេលវេលាជាមួយគរុនិស្សិត ៤០នាទីប្រើប្រាស់វិធីសាស្ត្រIBLក្នុងមេរៀនមួយ | | | | | |
| 19 | ខ្ញុំគិតថាវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក គឺជាវិធីសាស្ត្របង្រៀនមួយដែលល្អបំផុត | | | | | |
| 20 | ខ្ញុំគិតថាវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក អាចប្រើប្រាស់គ្រប់មេរៀន | | | | | |

ផ្នែកទី៥: ទស្សនៈផ្ទាល់ខ្លួននិង សំណូមពរ

1.តើលោក លោកស្រីមានទស្សនៈយោបល់អ្វីបន្ថែមទៀត ចំពោះវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ?

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

……………………………………………………………………………

2. នៅពេលមានឧបស័គ្គឬបញ្ហាក្នុងការប្រើប្រាស់ IBL តើលោកលោកស្រីមានដំណោះស្រាយដូចម្តេច ?

………………………………………………………………………………………………………

………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………

3.តើលោក លោកស្រីមានសំណូមពរ អ្វីខ្លះចំពោះវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………

បានឃើញនិងឯកភាព　　　　　　　　　　　　　　　　　　　　ហត្ថលេខា

គ្រូដឹកនាំបង្គោល　　　　　　　　　　　　　　　　　　　　អ្នកស្រាវជ្រាវ

# កម្រងសំណួរសម្រាប់គរុនិស្សិតវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

សួស្តីប្អូនៗខ្ញុំបាទឈ្មោះ គង់ ពេញ ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ខ្ញុំបាទបានរៀបចំការស្រាវជ្រាវលើប្រធានបទ« ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្រ្តបង្រៀននិងរៀនតាមបែបរិះរក IBL នៅវិទ្យាស្ថានគរុកោលល្យ រាជធានីភ្នំពេញ(១២+៤) » ។ អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោក លោកស្រីជាគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមេត្តាជួយសម្រួល និងផ្តល់ទិន្នន័យជាក់ស្តែង ដោយក្តីអនុគ្រោះ។ រាល់ទិន្នន័យទាំងឡាយ ដែលមានក្នុងកម្រងសំណួរមួយនេះ ខ្ញុំបាទសូមអនុញ្ញាតប្រើសម្រាប់តែសរសេរនិក្ខេបបទតែប៉ុណ្ណោះ ។ ខ្ញុំបាទសូមអំណរគុណយ៉ាងជ្រាលជ្រៅដល់គរុនិស្សិតវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលចំណាយពេលដ៏មានតម្លៃរបស់ខ្លួន ក្នុងការចូលរួមចែលរំលែកជាវិភាគទានដល់ការស្រាវជ្រាវដ៏មានសារៈសំខាន់របស់ខ្ញុំបាទមួយនេះ។

សូមអនុញ្ញាតដោយក្តីគោរព ដោយគូសសញ្ញា✓ ក្នុងប្រអប់ និងបំពេញចន្លោះតាមភាពជាក់ស្តែង

ផ្នែកទី១: ព័ត៌មានទូទៅ

១. ភេទ ស្រី ប្រុស

២. តួនាទី/ ឋានៈ គរុនិស្សិតឆ្នាំទី១ គរុនិស្សិតឆ្នាំទី២

៣. អាយុ ក្រោម២០ឆ្នាំ ពី២០-២៥ឆ្នាំ លើ២០ឆ្នាំ

៤. ឯកទេសកំពុងសិក្សា:……………………………

ផ្នែកទី២: អំពីគ្រួសារ

៥. តើឪពុកអ្នកបានបញ្ចប់ការសិក្សាកម្រិតណា?

ក្រោមមធ្យមសិក្សា ត្រឹមមធ្យមសិក្សា លើមធ្យមសិក្សា

៦. តើម្តាយអ្នកបានបញ្ចប់ការសិក្សាកម្រិតណា?

ក្រោមមធ្យមសិក្សា ត្រឹមមធ្យមសិក្សា លើមធ្យមសិក្សា

៧. តើអ្នកជាកូនដូចម្តេច ក្នុងគ្រួសារ?

ទោល ប្អូន បង

៨. តើជីវភាពគ្រួសារអ្នកស្ថិតក្នុងកម្រិតដូចម្តេច?

ក្រោមមធ្យម មធ្យម លើមធ្យម

៩. តើគ្រួសារអ្នកធ្លាប់បានដាស់តឿនអ្នកឲ្យខិតខំប្រឹងប្រែងរៀនសូត្របូទេ?

មិនធ្លាប់ ម្តងម្កាល ញឹកញាប់

១០. តើអ្នកពេញចិត្តនឹងការដាស់តឿនការសិក្សា របស់គ្រួសារអ្នកទេ?

មិនពេញចិត្ត ធម្មតា ពេញចិត្តណាស់

១១. តើគ្រួសារអ្នកពេញចិត្តអ្នកដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រូបង្រៀន(12+4) នេះឬទេ?

មិនពេញចិត្ត ធម្មតា ពេញចិត្តណាស់

១២. តើអ្នកទទួលបានការផ្គត់ផ្គង់នៃចំណាយរបស់អ្នកកម្រិតណា?

ខ្វះខាត គ្រប់គ្រាន់

ផ្នែកទី៣: អំពីការសិក្សា

១៣. នៅសាលាចំណេះទូទៅ តើក្រុមមុខវិជ្ជាអ្វីដែលអ្នកចូលចិត្តសិក្សា?

វិទ្យាសាស្ត្រពិត វិទ្យាសាស្ត្រសង្គម

១៤. តើការប្រឡងមធ្យមសិក្សាទុតិយភូមិ អ្នកទទួលបាននិទ្ទេសអ្វី ?

និទ្ទេស E និទ្ទេស D

និទ្ទេស C និទ្ទេស B និទ្ទេស A

១៥. តើអ្នកចូលចិត្តការស្រាវជ្រាវឬទេ?

មិនចូលចិត្ត ធម្មតា ចូលចិត្ត

១៦. តើអ្នកចូលចិត្តអានសៀវភៅនៅបណ្ណាល័យដែរទេ?

មិនចូលចិត្ត ធម្មតា ចូលចិត្ត

១៧. តើអ្នកមានសមត្ថភាពផ្នែកបច្ចេកវិទ្យាកម្រិតណា?

ក្រោមមធ្យម មធ្យម លើមធ្យម

១៨. តើអ្នកមានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេសកម្រិតណា?

ក្រោមមធ្យម មធ្យម លើមធ្យម

១៩. តើអ្នកចូលចិត្តសិក្សាស្វែងយល់ជីវិសាស្ត្របង្រៀននិងរៀនដែរឬទេ?

មិនចូលចិត្ត ធម្មតា ចូលចិត្ត

**ផ្នែកទី៤: ចំណេះដឹងផ្នែកវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក**

២០. តើអ្នកធ្លាប់សិក្សាស្វែងយល់ពីវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកដែរទេ?

ធ្លាប់ មិនធ្លាប់(បើមិនធ្លាប់សូមរំលងទៅសំណួរទី២០)

២១. តើអ្នកធ្លាប់សិក្សាស្វែងយល់ពីវិធីសាស្ត្របង្រៀននិងរៀនតាមរយៈអ្វី?

មានក្នុងខ្លឹមសារមេរៀន ការស្រាវជ្រាវ

ការធ្វើបទបង្ហាញ វគ្គបំប៉ន/សិក្ខាសាលា

២២. តើអ្នកពេញចិត្តវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ដែរទេ ?

មិនពេញចិត្ត ធម្មតា មិនពេញចិត្ត

២៣. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ជាវិធីដែលគាំទ្រគោលវិធីសិស្សមជ្ឈមណ្ឌល។

មិនច្បាស់ មិនពិត ពិតណាស់

២៤. វិធីសាស្ត្រ IBL គ្រូត្រូវមានភាពអត់ធ្មត់ និងជឿជាក់ថាសិស្សអាចធ្វើដោយខ្លួនឯងផ្អែកលើចំណេះមានស្រាប់។

មិនច្បាស់ មិនពិត ពិតណាស់

២៥. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក គឺពូនផ្តុំចំណេះដឹងសិស្សមិនមែនគម្ពីនិយមឡើយ។

មិនច្បាស់ មិនពិត ពិតណាស់

២៦. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកអាចប្រើប្រាស់គ្រប់មុខវិជ្ជាសិក្សាទាំងអស់ ប្រកបដោយប្រសិទ្ធិភាព។

មិនច្បាស់ មិនពិត ពិត

២៧. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកគឺជាបង្រៀនពិសោធន៍ តែការបង្រៀនពិសោធន៍ក៏មិនប្រាកដជា IBL ដែរ។

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

២៨. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក បង្រៀនតែលំនាំវិទ្យាសាស្ត្រ មិនមែនខ្លឹមសារទេ គឺIBL ប្រើលំនាំវិទ្យាសាស្ត្រដើម្បី បង្រៀនខ្លឹមសារ ។ មិនច្បាស់

មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

២៩.ការបង្រៀននិងរៀនតាមបែបរិះរកមានទម្រង់លក្ខណៈបែបវិទ្យាសាស្ត្រសង្គម.

មិនច្បាស់ មនត្រឹមត្រូវ ត្រឹមត្រូវណាស់

៣០. ការបង្រៀននិងរៀនតាមបែបរិះរកមានទម្រង់លក្ខលៈបែបវិទ្យាសាស្ត្រពិត

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

៣១. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកអាចបណ្តុះគំនិតបែបអ្នកវិទ្យាសាស្ត្រដល់សិស្ស។

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

៣២. វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកអាចធ្វើឲ្យពលរដ្ឋក្លាយជាអ្នកផលិតនៅពេលអនាគត

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

៣៣. វិធីសាស្ត្របង្រៀននិងររៀនតាមបែបរិះរកអាចធ្វើឲ្យមានកំណើនសេចដ្ឋកិច្ចជាតិនៅឆ្នាំ២០៣០

មិនច្បាស់ មិនត្រឹមត្រូវ ត្រឹមត្រូវណាស់

ផ្នែកទី៥: ការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក

*កម្រិតចង្អុលបង្ហាញ

1= មិនច្បាស់

2= មិនយល់ស្របទាំងស្រុង

3= យល់ស្របខ្លះៗ

4= យល់ស្រប

5= យល់ស្របទាំងស្រុង

| N | បរិយាយ | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|
| 1 | ខ្ញុំបានស្រាវជ្រាវ វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 2 | ខ្ញុំធ្លាប់បានធ្វើបទបង្ហាញនៅក្នុងថ្នាក់ស្តីពីវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 3 | ខ្ញុំបានចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់មិត្តរួមថ្នាក់ស្តីពីវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 4 | ខ្ញុំអាចប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក ប្រើប្រាស់វិធីសាស្ត្រ IBL | | | | | |
| 5 | ខ្ញុំមានចង់ប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនជាមួយសិស្សយ៉ាងសកម្ម | | | | | |
| 6 | ខ្ញុំបានស្វះស្វែងបង្កើតពាក្យគន្លឹះនៃខ្លឹមសារមេរៀនបានមួយចំនួនក្នុងពេលសិក្សា | | | | | |
| 7 | គ្រូឧទ្ទេសប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកមានលក្ខណៈរលូនជាមួយខ្ញុំ(មេរៀនខ្លះ) | | | | | |
| 7 | ខ្ញុំទទួលបានការពិនិត្យ តាមដាន និងវាយតម្លៃការប្រើប្រាស់វិធីសាស្ត្រIBLពីគ្រូឧទ្ទេស | | | | | |
| 8 | ខ្ញុំមានលទ្ធភាពធ្វើការបូកសរុបសំយោគខ្លឹមសារមេរៀនបានល្អប្រសើរ | | | | | |
| 9 | គ្រូឧទ្ទេសតែងតែប្រាប់ពីវត្ថុបំណងមេរៀនមកខ្ញុំមុន គ្រប់មេរៀនដែលខ្ញុំប្រើវិធីសាស្ត្រIBL | | | | | |
| 10 | គ្រូឧទ្ទេសតែងតែប្រាប់ខ្ញុំឲ្យអានមេរៀននៅក្នុងដំណើរការបង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 11 | គ្រូឧទ្ទេសច្រើនប្រើប្រាស់ជំហ៊ានIBL នៅក្នុងជំហ៊ានទី៣នៃលំនាំបង្រៀនរបស់គាត់ | | | | | |
| 12 | គ្រូឧទ្ទេចំណាយពេលវេលាជាមួយគរុនិស្សិត ៤០នាទីប្រើប្រាស់វិធីសាស្ត្រIBL ក្នុងមេរៀនមួយ | | | | | |
| 13 | ខ្ញុំព្រមទទួលយកការកែលម្អចំណុចខ្វះខាតពីគ្រូឧទ្ទេសយ៉ាងពេញចិត្ត | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| 14 | ខ្ញុំទទួលបានវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកបានយ៉ាងរលូនក្នុងមេរៀនមួយចំនួនពីគ្រូឧទ្ទេស | | | | | |
| 15 | ខ្ញុំទទួលបានការសម្របសម្រួលពីគ្រូឧទ្ទេសក្នុងការទាញយកសេចក្ដីសន្និដ្ឋានខ្លឹមសារមេរៀន | | | | | |
| 16 | ខ្ញុំគិតថាវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក គឺជាវិធីសាស្ត្របង្រៀនមួយដែលល្អបំផុត | | | | | |
| 17 | ខ្ញុំគិតថាវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក អាចប្រើប្រាស់គ្រប់មេរៀន | | | | | |

ផ្នែកទី៥: ទស្សនៈផ្ទាល់ខ្លួននិង សំណូមពរ

1.តើប្អូនៗមានទស្សនៈយោបល់អ្វីបន្ថែមទៀត ចំពោះវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

………………………………………………………………………………………… 2. នៅពេលមានឧបស័គ្គឬបញ្ហាក្នុងការប្រើប្រាស់ IBL តើប្អូនមានដំណោះស្រាយដូចម្ដេច?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

…………………………………………………………………………………………

3.តើលោក លោកស្រីមានសំណូមពរ អ្វីខ្លះចំពោះវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

…………………………………………………………………………………………

បានឃើញនិងឯកភាព — ហត្ថលេខា

គ្រូដឹកនាំបង្គោល — អ្នកស្រាវជ្រាវ

## កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

ខ្ញុំបាទឈ្មោះ គង់ ពេញ ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ខ្ញុំបាទបានរៀបចំការស្រាវជ្រាវលើប្រធានបទ« ប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក IBL នៅវិទ្យាស្ថានគរុកោលល្យ រាជធានីភ្នំពេញ(១២+៤) » ។ អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមគណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ មេត្តាជួយសម្រួល និងផ្តល់ទិន្នន័យជាក់ស្តែង ដោយក្តីអនុគ្រោះ។ រាល់ទិន្នន័យទាំងឡាយ ដែលមានក្នុងកម្រងសំណួរមួយនេះ ខ្ញុំបាទសូមអនុញ្ញាតប្រើសម្រាប់តែសរសេរនិក្ខេបបទតែប៉ុណ្ណោះ ។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលចំណាយពេលដ៏មានតម្លៃរបស់ខ្លួន ក្នុងការចូលរួមចែលរំលែកជាវិភាគទានដល់ការស្រាវជ្រាវដ៏មានសារៈសំខាន់របស់ខ្ញុំបាទមួយនេះ។

សូមអនុញ្ញាតដោយក្តីគោរព ដោយគូសសញ្ញា✓ ក្នុងប្រអប់ និងបំពេញចន្លោះតាមភាពជាក់ស្តែងរបស់គណៈគ្រប់គ្រងនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញតាមការគួរ។

ផ្នែកទី១: ព័ត៌មានទូទៅ

| | | |
|---|---|---|
| ១. ភេទ | ស្រី | ប្រុស |
| ២. តួនាទី/ ឋានៈ | នាយក/នាយិកា | នាយករង/នាយិការង |
| ៣. អាយុ | ក្រោម៣០ឆ្នាំ | លើស៣០ឆ្នាំ |

ផ្នែកទី២: គុណវុឌ្ឍិ

៤. តើលោកនាយក/នាយិកា ឬ លោកនាយករង/នាយិការង មានក្របខណ្ឌប្រភេទអ្វី?

គ្រូបង្រៀនកម្រិតមូលដ្ឋាន　　គ្រូបង្រៀនកម្រិតឧត្តម

៥. តើលោក លោកស្រី មានបទពិសោធគ្រប់គ្រងប៉ុន្មានឆ្នាំ?

| | |
|---|---|
| ១ឆ្នាំ-៥ឆ្នាំ | ៥ឆ្នាំ-១០ឆ្នាំ |
| ១០ឆ្នាំ-១៥ឆ្នាំ | ១៥ឆ្នាំឡើងទៅ |

៦. តើលោក លោកស្រី ទទួលបានសញ្ញាបត្រចុងក្រោយកម្រិតអ្វី?

សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សញ្ញាបត្របរិញ្ញាបត្រប(ឯកទេស:..........................................................)

សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់(ឯកទេស:................................................)

សញ្ញាបត្របណ្ឌិត (ឯកទេស:...................................................)

ផ្នែកទី៣: ចំណេះដឹងស្តីពីវិធីសាស្ត្របង្រៀននិងរៀន IBL

៧. តើលោក លោកស្រីធ្លាប់ស្វែងយល់ពីវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក ឬទេ?

ធ្លាប់　　មិនធ្លាប់(បើមិនធ្លាប់សូមរំលងទៅសំណួរទី៩)

៨. តើលោកលោកស្រីធ្លាប់សិក្សាស្វែងយល់ពីវិធីសាស្ត្របង្រៀននិងរៀនតាមរយៈអ្វី?

វគ្គបំប៉ន ការស្រាវជ្រាវ ផ្សេងៗ

៩. តើវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកមានសារៈសំខាន់សម្រាប់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញឬទេ?

មានសារៈសំខាន់ មិនមានសារៈសំខាន់

*កម្រិតចង្អុលបង្ហាញ

1= មិនច្បាស់

2= មិនយល់ស្របទាំងស្រុង

3= យល់ស្របខ្លះៗ

4= យល់ស្រប

5= យល់ស្របទាំងស្រុង

| N | បរិយាយ | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|
| 1 | គណៈគ្រប់គ្រងយកចិត្តទុកដាក់ខ្ពស់ចំពោះវិធីសាស្ត្របង្រៀននិងរៀន | | | | | |
| 2 | គណៈគ្រប់គ្រងពេញចិត្តនឹងវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 3 | គណៈគ្រប់គ្រងបានបើកវគ្គបំប៉នវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកឲ្យគ្រូឧទ្ទេសសិក្សា | | | | | |
| 4 | គណៈគ្រប់គ្រងអនុញ្ញាត លើកទឹកចិត្តឲ្យគ្រូឧទ្ទេសប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 5 | គណៈគ្រប់គ្រងបានអនុញ្ញាតនិងលើកទឹកចិត្តគ្រូឧទ្ទេសឲ្យសិក្សាវិធីសាស្ត្រ IBL បន្ថែមនៅបរទេស | | | | | |
| 6 | គណៈគ្រប់គ្រងមានកម្មវិធីពិនិត្យតាមដានវាយការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 7 | គណៈគ្រប់គ្រងបានត្រួតពិនិត្យ តាមដាន និងវាយតម្លៃការប្រើប្រាស់វិធីសាស្ត្រ IBLរបស់គ្រូឧទ្ទេស | | | | | |
| 8 | ការបង្រៀននិងរៀនតាមបែបរិះរកមានទម្រង់លក្ខណៈបែបវិទ្យាសាស្ត្រសង្គម | | | | | |
| 9 | ការបង្រៀននិងរៀនតាមបែបរិះរកមានទម្រង់លក្ខលៈបែបវិទ្យាសាស្ត្រពិត | | | | | |
| 10 | គ្រូឧទ្ទេសមិនចាំបាច់ប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកនោះទេ | | | | | |
| 11 | គ្រូឧទ្ទេសចាំបាច់ត្រូវប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក | | | | | |
| 12 | គ្រូឧទ្ទេសត្រូវបន្តស្រាវជ្រាវវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកបន្ថែមឲ្យបានច្បាស់លាស់ | | | | | |
| 13 | គ្រូឧទ្ទេសត្រូវប្រើវិធីសាស្ត្របង្រៀននិងរៀនឲ្យបានគ្រប់មេរៀន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| 14 | វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកអាចបណ្តុះគំនិតបែបអ្នកវិទ្យាសាស្ត្រដល់សិស្ស | | | | | |
| 15 | វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកអាចធ្វើឲ្យពលរដ្ឋក្លាយជាអ្នកផលិតនៅពេលអនាគត | | | | | |
| 16 | វិធីសាស្ត្របង្រៀននិងររៀនតាមបែបរិះរកអាចធ្វើឲ្យមានកំណើនសេចដ្ឋកិច្ចជាតិនៅឆ្នាំ២០៣០ | | | | | |
| 17 | | | | | | |

ផ្នែកទី៤: សំណូមពរ

តើលោក លោកស្រីមានសំណូមពរ និងទស្សនៈយោបល់អ្វីបន្ថែមទៀត ចំពោះវិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរក?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

………………………………………………………………………………………

បានឃើញនិងឯកភាព ហត្ថលេខា

គ្រូដឹកនាំបង្គោល អ្នកស្រាវជ្រាវ